ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨







ក្រុមប្រឹក្សាសកម្មភាពជនពិការ

ឆ្នាំ ២០១៤

ការបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាសកម្មភាពជនពិការ
សហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
រក្សាសិទ្ធិគ្រប់យ៉ាងដោយ ក្រុមប្រឹក្សាសកម្មភាពជនពិការ ឆ្នាំ២០១៤
បោះពុម្ពនៅរាជធានីភ្នំពេញ

**ចម្លង**

ការបោះពុម្ពឡើងវិញ ឬថតចម្លងនូវខ្លឹមសារដែលមាននៅក្នុងសៀវភៅផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ នេះ សម្រាប់គោលបំណងផ្សេងទៀត រួមទាំងការប្រកាសផ្សាយជាសាធារណៈ និងផ្សាយពាណិជ្ជកម្ម ត្រូវបានហាមឃាត់ ក្នុងករណីដែលគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំការអនុញ្ញាតត្រូវដាក់ជូនទៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ តាមរយៈអាសយដ្ឋានអ៊ីម៉ែល info@dac.org.kh ដោយភ្ជាប់ជាមួយនូវគោលបំណង និងចំនួននៃការផលិតឡើងវិញនោះ។

ឧបត្ថម្ភការរៀបចំផែនការដោយ៖

ឧបត្ថម្ភការបោះពុម្ពដោយ៖

មានជនពិការកម្ពុជា

# ៣០១

ពាន់នាក់

រស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ការប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដើម្បីបង្ហាញឲ្យឃើញអំពីឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម ពិសេសការបញ្ចូលជនពិការទៅក្នុងកិច្ចអភិវឌ្ឍសម្រាប់សង្គមជាតិ និងពិភពលោកទាំងមូល។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាសកម្មភាពជនពិការ សំរាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨

នៅក្នុងពិភពលោក មានជនពិការប្រមាណជាង ១ពាន់លាននាក់ ក្នុងនោះជនពិការចំនួន ២០០លាននាក់ កំពុងប្រឈមមុខនឹងជីវភាពរស់នៅដោយលំបាកៗ។ នៅប៉ុន្មានឆ្នាំខាងមុខ បញ្ហាពិការភាព នឹងក្លាយជាក្តីបារម្ភកាន់តែធំធេងដោយសារអត្រាពិការភាពកាន់តែកើនឡើង នេះដោយសារតែបញ្ហាបណ្តាល មកពីជំងឺរ៉ាំរ៉ៃផ្សេងៗ ដូចជា ទឹកនោមផ្អែម មហារីក ជំងឺសរសៃឈាមបេះដូង ដាច់សរសៃឈាមក្នុងខួរក្បាលជាដើម។ កត្តានេះទាមទារឲ្យយើងទាំងអស់គ្នា ត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកដំណោះស្រាយជាបន្ទាន់។ ដោយឡែកនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក មានជនពិការប្រមាណ ៦៥០លាននាក់ ស្មើនឹង១៥% នៃប្រជាជនសរុប ដែលកំពុងត្រូវបានគេបំភ្លេច ឬមើលរំលងៗ។

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ដ៏មហាវិនាសកម្មដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ដែលក្នុងនោះមានអត្រាជនពិការខ្ពស់ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពរងគ្រោះមួយចំនួនដែលនាំឲ្យមានពិការភាព ដូចជាគ្រោះថ្នាក់ដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ក្រៅពីនោះក៏មានគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងៗទៀត។

ជនពិការ គឺជាមនុស្សដែលត្រូវបានយកចិត្តទុកដាក់ និងមានសិទ្ធិដូចជនមិនពិការដែរ។ ជនពិការនិងកុមារពិការ ត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់សកម្មភាពអភិវឌ្ឍ មិនត្រូវទុកជនពិការឲ្យនៅដាច់ដោយឡែកនោះទេ។ ត្រូវធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថ ការយល់ឃើញរបស់សង្គមចំពោះជនពិការ ក្នុងការទទួលស្គាល់សកម្មភាព និងសំឡេងរបស់ជនពិការ ដែលនាំមកនូវការលើកកម្ពស់ដល់ការអភិវឌ្ឍសង្គម។ ជនពិការនិងកុមារពិការមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយកឈ្នះនូវរាល់ឧបសគ្គរាំងស្ទះផ្សេងៗដោយខ្លួនឯង ប្រសិនបើ...

បញ្ចូលពួកគេទៅក្នុងគ្រប់វិស័យដោយផ្អែកលើគោលការណ៍សិទ្ធិស្មើគ្នាដើម្បីធ្វើឲ្យជីវិតពួកគេ និងគ្រួសារមានភាពប្រសើរឡើង។

ស្របតាមដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ សុខុមាលភាពជនពិការបានប្រសើរឡើងជាជំហានៗ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ និងចូលជាធរមាននៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣។ ជាមួយគ្នានេះ យើងពិតជាមានមោទនភាពដែលព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសទី១ ក្នុងចំណោមរដ្ឋជាសមាជិករបស់គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលបានអនុម័តលើទសវត្សរ៍ ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈោន "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" និងបានប្រកាសដាក់ឲ្យអនុវត្តកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ដែលយុទ្ធសាស្ត្រនេះត្រូវបានទទួលស្គាល់ថាជាកិច្ចព្រមព្រៀងថ្នាក់តំបន់លើកដំបូង ដែលមានគោលដៅអភិវឌ្ឍរួមបញ្ចូលផ្នែកពិការភាព និងជាផែនទីចង្អុលផ្លូវសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងការលើកកម្ពស់ជីវភាព និងសិទ្ធិជនពិការប្រមាណ ៦៥០លាននាក់នៅក្នុងតំបន់។ ក្រៅពីនេះ កម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាជាច្រើន មានជាអាទិ៍ៈ អនុសញ្ញាអូតាវ៉ាស្តីពីការហាមប្រាម ការប្រើប្រាស់ ការស្តុកទុក ការផលិត ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន ក្របខ័ណ្ឌការងារទសវត្សរ៍ប៊ីវ៉ាកូ និងប៊ីវ៉ាកូបូក៥។ កម្ពុជាបានចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដែលទាក់ទងនឹងជនពិការ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ត្រង់ចតុកោណទី៤ មុំទី៣ អាទិភាពទី៤ ចំណុចទី៣ "ការបន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ តាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ ការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការជំរុញកិច្ចការពារ និងលើកកម្ពស់សិទ្ធិនិងសុខុមាលភាពជនពិការ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ព្រមទាំងការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃសេវារបស់មូលនិធិជនពិការ"។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨នេះ មានទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗចំនួន១០ ផ្តោតលើការកាត់បន្ថយភាពក្រីក្ររបស់ជនពិការ ការផ្តល់សេវាសុខភាពប្រកបដោយគុណភាពនិងសមភាព ព្រមទាំងការស្តារលទ្ធភាពពលកម្មកាយសម្បទា និងសតិបញ្ញា ការផ្តល់សេវាយុត្តិធម៌ ការពារការរើសអើង ការរំលោភបំពាន ការប្រមាថ និងការកេងប្រវ័ញ្ចលើជនពិការ ការអប់រំ ការចូលរួម ក្នុងការសម្តែងមតិ ទទួលព័ត៌មាន និងចូលរួមជីវភាពនយោបាយ ការអភិវឌ្ឍនិង កែសម្រួលឲ្យមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនបម្រើសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនងចំពោះជនពិការ ការធានាសមភាពយេនឌ័រ និងការលើកកម្ពស់សមត្ថភាពស្ត្រីនិងកុមារពិការ ការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយថ្នាក់អន្តរជាតិ។

ខ្ញុំយល់ឃើញថា ផែនការយុទ្ធសាស្ត្រនេះ គឺជាឧបករណ៍គោលនយោបាយជាចាំបាច់ ដែលទាមទារឲ្យមានការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ និងកែលម្អជាប្រចាំដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនាពេលអនាគត។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនេះ [illegible] បាននូវដំណោះស្រាយជាក់លាក់ និងបទពិសោធល្អៗ សម្រាប់រួមចំណែកដល់ការ [illegible]

ឲ្យកាន់តែមានប្រសិទ្ធភាព។ នេះគឺជាគោលបំណងរបស់យើង ដើម្បីជំរុញសង្គមកម្ពុជាក្នុងការបោះជំហានឆ្ពោះទៅរកការលុបបំបាត់ឧបសគ្គនានា និងផ្តល់ឱកាសដល់ជនពិការ ដើម្បីសង្គមមួយសម្រាប់យើងទាំងអស់គ្នា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល និងបងប្អូនជនពិការ ដែលបានរួមចំណែកដល់ការរៀបចំកសាងផែនការយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ដែលជាស្នាដៃទុកជាប្រវត្តិសាស្ត្រសម្រាប់ជនពិការ។

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ទាមទារអភិក្រមផ្អែកលើកម្មវិធីជានាំឲ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីដោយផ្អែកលើបញ្ហាដែលនាំឲ្យមានពិការភាព គួរលើកទឹកចិត្តឲ្យមានសកម្មភាពនានា ដែលជំរុញ ឬគាំទ្រដល់ការពង្រឹងបន្ថែមនូវការអនុវត្តភាពនានា ក៏ដូចជាការពង្រីកនូវអត្ថប្រយោជន៍ និងផលចំណេញបន្ថែមសម្រាប់សង្គម។

ក្នុងន័យដូចដែលបានលើកឡើងខាងលើនេះ ខ្ញុំសូមស្នើដល់ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សូមយកចិត្តទុកដាក់ចូលរួមអនុវត្តការងារ ពាក់ព័ន្ធពិការភាព ពិសេសផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់សម្រាប់សង្គមជាតិយើង ពិសេសការបង្កើនការយកចិត្តទុកដាក់គិតគូរលើបញ្ហាពិការភាព ការការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការដាក់បញ្ចូលពិការភាពទៅក្នុងការអភិវឌ្ឍគ្រប់លំដាប់ថ្នាក់ឆ្ពោះទៅរកសង្គមមួយសម្រាប់ទាំងអស់គ្នា ដើម្បីធ្វើឲ្យសិទ្ធិក្លាយជាការពិត។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានកិត្តិយសនិងសេចក្តីសោមនស្សរីករាយ សូមប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ដើម្បីបង្ហាញឲ្យឃើញអំពីឆន្ទៈនយោបាយ ការប្តេជ្ញាចិត្តដ៏រឹងមាំ របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម ពិសេសការបញ្ចូលជនពិការទៅក្នុងកិច្ចអភិវឌ្ឍសម្រាប់សង្គមជាតិ និងពិភពលោកទាំងមូល។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ក្នុងជួររាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍនឹងយកផែនការយុទ្ធសាស្ត្រនេះទៅប្រើប្រាស់ជាត្រីវិស័យសម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**



ឯកឧត្តម វង សូត

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាសកម្មភាពជនពិការ
DISABILITY ACTION COUNCIL

# សេចក្តីថ្លែងអំណរគុណ
# របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
# និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ

ក្នុងនាមក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមសម្តែងការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះស្ម័គ្រជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជា **ប្រធានកិត្តិយស** ក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលបានគាំទ្រយ៉ាងពេញទំហឹង និងយកចិត្តទុកដាក់ខ្ពស់លើវិស័យពិការភាព ពិសេសបានដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ ដែលបានកំណត់អំពីសកម្មភាពជាអាទិភាពយ៉ាងជាក់លាក់ដើម្បីបុព្វហេតុរបស់បងប្អូនជនពិការ។ ឈរលើមូលដ្ឋាននេះ បញ្ហាពិការភាពត្រូវបានចាត់ទុកជាបញ្ហាអន្តរវិស័យ ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨។ ក្នុងន័យនេះ ខ្ញុំមានមោទនភាពចំពោះផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ដែលត្រូវបានរៀបចំឡើងក្រោមការដឹកនាំសម្របសម្រួលរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ គឺជាសមិទ្ធផល និងជាប្រវត្តិសាស្ត្រថ្មីមួយទៀតក្នុងវិស័យពិការភាព ដែលសម្រេចបានក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជា **ប្រធានកិត្តិយស** ក្រុមប្រឹក្សាសកម្មភាពជនពិការ។

ខ្ញុំសូមថ្លែងអំណរគុណ ចំពោះទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ជំនួយបច្ចេកទេសនិងថវិកា ដើម្បីកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ដោយទទួលបានជោគជ័យដ៏ត្រចះត្រចង់។ ខ្ញុំក៏សូមថ្លែងអំណរគុណ និងសូមកោតសរសើរជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មកពីបណ្តាស្ថាប័នជំនាញ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ពិសេសបងប្អូនជនពិការ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះឱ្យសម្រេចបានជារូបរាងឡើង។

ប្រទេសកម្ពុជា មានយន្តការសម្រាប់ដោះស្រាយផលលំបាករបស់បងប្អូនជនពិការ ដែលយន្តការទាំងនោះបាននិងកំពុងយកចិត្តទុកដាក់អនុវត្ត បម្រើផលប្រយោជន៍របស់បងប្អូនជនពិការ។

អាសយដ្ឋាន: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ
អ៊ីម៉ែល: dac@dac.org.kh គេហទំព័រ: www.dac.org.kh
Address: MoSVY, #788 Monivong Blvd., Phnom Penh
ទូរស័ព្ទ: (855) 23 727 428
ទូរសារ: (855) 23 727 428

ដោយប្រសិទ្ធភាព។ បើទោះបីជាការលើកកម្ពស់ ផ្តល់លទ្ធភាពទទួលបានសេវាពិការភាព និងការអភិវឌ្ឍសេវានៅតែមានកម្រិត និងជាក្តីកង្វល់របស់បងប្អូនជនពិការ ប៉ុន្តែរាជរដ្ឋាភិបាលមានឆន្ទៈនិងការប្តេជ្ញាចិត្តធ្វើការកែទម្រង់ស្ថាប័ន និងវិធីសាស្ត្រដោះស្រាយ ដែលបង្កនូវលក្ខណៈងាយស្រួលដល់បងប្អូនជនពិការ តាមរយៈការផ្ទេរបច្ចេកវិទ្យា កំណែទម្រង់ច្បាប់ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដើម្បីឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ជនពិការ។

របាយការណ៍ចន្លោះជំរឿនឆ្នាំ២០១៣ របស់ក្រសួងផែនការ បានបង្ហាញអំពីចំនួនជនពិការកម្ពុជាចំនួន ៣០១,៦២៩នាក់ ស្មើនឹង២.០៦% នៃចំនួនប្រជាជនសរុប១៤,៦៧៦,៥៩១នាក់ ក្នុងឆ្នាំ២០១៣។ ក្នុងនោះបុរសពិការមានចំនួន១៥៧,០០៨នាក់ស្មើនឹង៥២.០៥% និងស្ត្រីពិការមានចំនួន ១៤៤,៦២២នាក់ ស្មើនឹង៤៧.៩៥%។ កុមារពិការអាយុពី០ឆ្នាំដល់១៤ឆ្នាំ មានចំនួន ៣២,០៥៦នាក់ ស្មើនឹង១០.៦៣ភាគរយនៃជនពិការសរុប ដែលយើងអាចធ្វើជាមូលដ្ឋានក្នុងការកំណត់សកម្មភាពជាក់ស្តែង និងការធ្វើវិនិយោគប្រកបដោយជោគជ័យសម្រាប់ជនពិការគ្រប់រូប។

នៅព្រះរាជាណាចក្រកម្ពុជា បញ្ហាពិការភាពគឺជាបញ្ហាប្រឈមមួយដែលត្រូវយកចិត្តទុកដាក់ខ្ពស់ ដែលបញ្ហានេះធ្វើឱ្យខាតបង់ធនធានជាតិ ប៉ះពាល់លើសេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាជន។ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងដោះស្រាយយ៉ាងយកចិត្តទុកដាក់ទប់ស្កាត់បញ្ហាពិការភាព តាមរយៈការរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាជាច្រើន។

ឯកសារយុទ្ធសាស្ត្រនេះ រៀបចំឡើងដោយអនុលោមតាមគោលការណ៍ណែនាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានសង្គតិភាពជាមួយវដ្តនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏ដូចជាផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមប្រឹក្សាសកម្មភាពជនពិការ និងស្ថាប័នជំនាញជាច្រើន បានផ្តល់ធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ និងបានដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្រចំនួន១០ ដើម្បីឆ្លើយតបនឹងបញ្ហាពិការភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីធានាឱ្យមានការឯកភាពគ្នា និងភាពជាម្ចាស់របស់អ្នកពាក់ព័ន្ធ យើងក៏បានរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាពិការភាពតាមរយៈវិធានការការពារ ទប់ស្កាត់ លើកកម្ពស់ និងអភិវឌ្ឍបរិស្ថានរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ផែនការយុទ្ធសាស្ត្រនេះ ក៏បានសង្កត់ធ្ងន់ទៅលើការកសាងសមត្ថភាពស្ថាប័ន ចំណេះដឹងជំនាញវិជ្ជាជីវៈ ការផ្តួចផ្តើមបង្កើតមុខរបរ ការកាត់បន្ថយនិងឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើង ការវាយតម្លៃចំពោះជនពិការ និងការទទួលខុសត្រូវរបស់ស្ថាប័នដែលទទួលខុសត្រូវអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកជំនាញការទាំងអស់ ពិសេសបងប្អូនជនពិការ ដែលបានផ្តល់នូវធាតុចូលល្អៗ ជួយគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងទាន់ពេលវេលា។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ**

**វង សូត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិ

# ស្តីពី

# ពិការភាព ២០១៤-២០១៨

ក្រុមប្រឹក្សាសកម្មភាពជនពិការ

ឆ្នាំ២០១៤

# មាតិកា


សារលិខិតសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

សេចក្ដីថ្លែងអំណរគុណ

១-សេចក្ដីផ្ដើម ........ ១

២-ចក្ខុវិស័យ ........ ២

៣-បេសកកម្ម ........ ២

៤-គោលបំណង និងគោលដៅ ........ ៣

៥-ក្របខណ្ឌយុទ្ធសាស្ត្រ ........ ៣

*៥.១-គោលការណ៍ណែនាំ* ........ ៣

*៥.២-ការវិភាគជាយុទ្ធសាស្ត្រ* ........ ៤

*៥.៣-ទិសដៅជាយុទ្ធសាស្ត្រ* ........ ៨

ទិសដៅជាយុទ្ធសាស្ត្រទី១ ........ ៨

ទិសដៅជាយុទ្ធសាស្ត្រទី២ ........ ១០

ទិសដៅជាយុទ្ធសាស្ត្រទី៣ ........ ១១

ទិសដៅជាយុទ្ធសាស្ត្រទី៤ ........ ១២

ទិសដៅជាយុទ្ធសាស្ត្រទី៥ ........ ១៣

ទិសដៅជាយុទ្ធសាស្ត្រទី៦ ........ ១៥

ទិសដៅជាយុទ្ធសាស្ត្រទី៧ ........ ១៦

ទិសដៅជាយុទ្ធសាស្ត្រទី៨ ........ ១៧

ទិសដៅជាយុទ្ធសាស្ត្រទី៩ ........ ១៩

ទិសដៅជាយុទ្ធសាស្ត្រទី១០ ........ ២០

៦-សកម្មភាពការងារ ........ ២១

*៦.១- ដំណាក់កាលសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព២០១៤-២០១៨* .. ២១

*៦.២- ការបង្កើតកម្មវិធីនិងកសាងផែនការសកម្មភាព* ........ ២៣

៧-ធនធានហិរញ្ញវត្ថុ ........ ២៤

៨-ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ........ ២៥

*៨.១-គោលការណ៍ទូទៅ* ........ ២៥

*៨.២-វិធីសាស្ត្រ* ........ ២៦

*៨.៣-ការគ្រប់គ្រងនិងវេទិកាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត* ........ ២៦

៩-សេចក្ដីសន្និដ្ឋាន ........ [illegible]

សទ្ទានុក្រម

## ១. សេចក្តីផ្តើម

១- ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា វិស័យពិការភាពមានការអភិវឌ្ឍរីកចម្រើនគួរឲ្យកត់សម្គាល់ និងទទួលបានសមិទ្ធផលធំធេងជាបន្តបន្ទាប់។ ស្ថានភាពរបស់ជនពិការកម្ពុជាមានភាពល្អប្រសើរឡើងជាលំដាប់។ គោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់វិស័យពិការភាពត្រូវបានដាក់ឲ្យអនុវត្តប្រកបដោយផ្លែផ្កា។ មជ្ឈដ្ឋានជាតិនិងអន្តរជាតិនិងបងប្អូនជនពិការមានការសប្បាយរីករាយ ចំពោះការគិតគូរនិងការយកចិត្តទុកដាក់ខ្ពស់របស់សម្តេចតេជោ ប្រមុខរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា និងអង្គការដៃគូនានាចំពោះសុខុមាលភាពជនពិការ។

២- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពរយៈពេល៥ឆ្នាំនេះ មានឈ្មោះថា *"ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨"* ត្រូវបានរៀបចំឡើងទៅតាមទម្រង់នៃសេចក្តីជូនដំណឹងលេខ៤៣៣.សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការរៀបចំតាក់តែងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា។

៣- ការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ គឺជាការបន្តការអនុវត្តលើផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមឆ្នាំ២០០៩-២០១១ និងដែលបានបន្តរហូតដល់ឆ្នាំ២០១៣។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ គឺជាមូលដ្ឋានគ្រឹះនិងជាឆ្អឹងខ្នងដ៏សំខាន់ដែលមិនអាចខ្វះបាន ក្នុងការជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រ អ៊ិនឈាន់ **"ធ្វើឲ្យសិទ្ធិក្លាយជាការពិត"** ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យពិការភាព។

៤- ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ កន្លងមកនេះ ព្រះរាជាណាចក្រកម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការជាផ្លូវការ ដែលនេះជាការវិវត្តភាពថ្មីមួយទៀតនៃវិស័យពិការភាពនៅកម្ពុជា និងជាការលើកទឹកចិត្តបន្ថែមទៀតដល់បងប្អូនជនពិការ។ ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកក្នុងការអនុវត្តយុទ្ធសាស្ត្រ អ៊ិនឈាន់"ធ្វើឲ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ទសវត្សរ៍ជនពិការឆ្នាំ២០១៣-២០២២។

៥- ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ រដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ និងបានប្រកាសដាក់ឲ្យប្រើ នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។ ច្បាប់នេះ គឺជាការលើកទឹកចិត្តនិងកំណត់កាតព្វកិច្ចដល់គ្រប់ក្រសួង ស្ថាប័នឯកជន អង្គការមិនមែនរដ្ឋាភិបាល ក្នុងការស្រូបទាញនិងប្រើប្រាស់សក្តានុពលនៃជនពិការ តាមរយៈការដាក់បញ្ចូលជនពិការទៅក្នុងសកម្មភាពរបស់ខ្លួនព្រមទាំងលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍទាំងអស់ដែលបានដាក់បញ្ចូលជនពិការទៅក្នុងគម្រោងអភិវឌ្ឍនានារបស់ខ្លួន ក្នុងទិសដៅធ្វើសមាហរណកម្មជនពិការទៅក្នុងសង្គមជាតិ និងសហគមន៍អន្តរជាតិ។/.

៦- រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ត្រង់ចតុកោណទី៤ មុំទី៣ អាទិភាពទី៤ ចែងថា "ការបន្តអនុវត្តគោលនយោបាយជាតិចំពោះជនពិការ តាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ ការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ការជំរុញកិច្ចការពារលើកកម្ពស់សិទ្ធិនិងសុខុមាលភាពជនពិការស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ព្រមទាំងការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃសេវារបស់មូលនិធិជនពិការ។"

៧- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ លើកឡើងពីវិធានគោលនយោបាយជាអាទិភាព សម្រាប់ការអនុវត្តកម្មវិធីកំណែទម្រង់នានានៃវិស័យពិការភាព សំដៅលើកកម្ពស់សមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ក្នុងទិសដៅបង្កើតកាលានុវត្តភាពការងារសម្រាប់ជនពិការ កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍការងារសំខាន់ៗរបស់វិស័យពិការភាពនៅកម្ពុជា។

៨- ទន្ទឹមនឹងនេះ ដើម្បីធានាដល់ការពិភាក្សានិងពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធភាពជាមួយដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ពិសេសជនពិការក្នុងការរៀបចំធាតុចូលរបស់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាសកម្មភាពជនពិការ បានអនុវត្តកិច្ចការសំខាន់ៗដែលបានធ្វើឡើងជាបីជំហាន។ នៅក្នុងជំហានទី១ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ចំនួន២តំបន់ ដែលតំបន់ទី១គឺតំបន់ទិសពាយ័ព្យកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅខេត្តសៀមរាប និងតំបន់ទី២គឺតំបន់ទិសនិរតីកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅខេត្តព្រះសីហនុ។ ជំហានទី២ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងជនពិការជាច្រើននាក់។ ជំហានទី៣ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានរៀបចំកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងចុងក្រោយនៃផែនការនេះ ជាមួយតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលបន្ថែមទៀត។

៩- ដើម្បីអនុវត្តភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពទាក់ទិននឹងពិការភាព តាមរយៈអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ។

## ២- ចក្ខុវិស័យ

ជនពិការនិងក្រុមគ្រួសារ មានគុណភាពជីវិតល្អប្រសើរ និងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរ ព្រមទាំងមានការដាក់បញ្ចូលបញ្ហាពិការភាពក្នុងគ្រប់វិស័យ។

## ៣- បេសកកម្ម

ជំរុញការចូលរួមពីស្ថាប័នរដ្ឋ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា សម្រាប់ការដាក់បញ្ចូលបញ្ហាពិការភាពទៅក្នុងការងារសង្គម ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ៤- គោលបំណងនិងគោលដៅ

### ៤-១.គោលបំណង

- ធ្វើឲ្យជីវភាពរស់នៅរបស់ជនពិការនិងគ្រួសារមានភាពប្រសើរឡើង គោរពសេចក្តីថ្លៃថ្នូរពីកំណើត និងការរស់នៅដោយឯករាជ្យ ព្រមទាំងសុខុមាលភាពពេញលេញ។
- លើកកម្ពស់ភាពស្មើគ្នាចំពោះមុខច្បាប់ និងការទទួលបានសេវាយុត្តិធម៌ ការពារជនពិការពីការធ្វើទារុណកម្ម ការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា និងដំណោះស្រាយត្រូវមានអាសន្ន ព្រមទាំងលើកស្ទួយសមភាពស្ត្រីពិការ កុមារពិការ និងជនពិការគ្រប់ប្រភេទ។

### ៤-២. គោលដៅ

- ផ្តល់សេវាគាំពារសង្គម អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ការងារ អាជីព និងសេវាកម្មនានាជួយជនពិការ។
- ផ្តល់សិទ្ធិអំណាច តាមរយៈការចូលរួមការសម្រេចចិត្ត និងការធ្វើនយោបាយរបស់ជនពិការក្នុងសង្គម។
- កែលម្អឱកាសប្រើប្រាស់ស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនបម្រើជាសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង។

## ៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាម និងរបបប្រល័យពូជសាសន៍ដ៏មហាវិនាសកម្មដែលបានបន្សល់ទុកផលវិបាកជាច្រើនដែលក្នុងនោះមានអត្រាជនពិការខ្ពស់ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពងាយរងគ្រោះមួយចំនួនដែលនាំឲ្យមានពិការភាពផងដែរ គ្រោះថ្នាក់ដោយសារគ្រាប់មីននិងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា និងមូលហេតុផ្សេងៗ។

ជនពិការនិងកុមារពិការត្រូវបានដាក់បញ្ចូលទៅក្នុងគ្រប់សកម្មភាពអភិវឌ្ឍន៍ ដោយមិនបានទុកជនពិការឲ្យនៅដាច់ដោយឡែកនោះទេ ព្រមទាំងធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថ ការយល់ឃើញរបស់សង្គមចំពោះជនពិការក្នុងការទទួលស្គាល់សកម្មភាពនិងសំឡេងរបស់ជនពិការ ពិតជានឹងនាំមកនូវការលើកកម្ពស់ផលការអភិវឌ្ឍសង្គម។ ជនពិការនិងកុមារពិការមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយកឈ្នះនូវរាល់ឧបសគ្គនានាផ្សេងៗដោយខ្លួនឯង ដូច្នេះការដាក់បញ្ចូលពួកគេក្នុងគ្រប់វិស័យដោយផ្អែកលើគោលការណ៍សិទ្ធិស្មើគ្នានឹងធ្វើឲ្យជីវិតពួកគេនិងសហគមន៍មានភាពប្រសើរឡើង។

### ៥.១. *គោលការណ៍ណែនាំ*

១- គោរពនូវសេចក្តីថ្លៃថ្នូរស្មើភាពរបស់បុគ្គល ដែលរួមមានទាំងសេរីភាពការជ្រើសរើសដោយខ្លួនឯងនិងឯករាជ្យភាពនៃបុគ្គល។

២- ការមិនរើសអើង។

៣- ជំរុញការចូលរួមពេញលេញប្រកបដោយប្រសិទ្ធភាព និងការដាក់បញ្ចូលទៅក្នុងសង្គម។

៤- គោរពភាពផ្សេងគ្នានិងការទទួលយកជនពិការជាផ្នែកនៃភាពចម្រុះមនុស្សជាតិ និងមនុស្សធម៌។



៥- ផ្តល់ឱកាសស្មើគ្នា។

៦- ផ្តល់ការសម្របសម្រួលសមស្រប។

៧- លើកកម្ពស់សមភាពរវាងបុរសនិងស្ត្រី។

៨- គោរពសមត្ថភាពវិវត្តរបស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការក្នុងការការពារអត្តសញ្ញាណរបស់ខ្លួន។

៩- ការពារសិទ្ធិនិងសេរីភាពរបស់ជនពិការ។

១០- ការពារផលប្រយោជន៍របស់ជនពិការ។

១១- ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ។

១២- ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពពលកម្មក្នុងការចូលរួមពេញលេញ និងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គម។

### ៥.២. *ការវិភាគជាយុទ្ធសាស្ត្រ*

ដើម្បីឱ្យមានការឆ្លើយតបជាមួយគោលបំណងនិងអាទិភាពនៃលិខិតបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិ ឯកសារសំខាន់ៗមួយចំនួនត្រូវបានលើកយកមកពិចារណានៅពេលធ្វើការវិភាគជាយុទ្ធសាស្ត្រ។

ឯកសារទាំងនោះរួមមាន៖

- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥
- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣
- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
- គោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ
- ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ
- អនុក្រឹត្យស្តីពីការកំណត់អត្រានិងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ
- អនុក្រឹត្យស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- យុទ្ធសាស្ត្រអ៊ិនឈាន់ **"ធ្វើឱ្យសិទ្ធិក្លាយជាការពិត"**
- ផែនការសកម្មភាពជាតិស្តីពីជនពិការរួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមឆ្នាំ២០០៩-២០១១
- អនុសញ្ញាស្តីពីការហាមប្រាម ការប្រើប្រាស់ ការស្តុកទុក ការផលិត និងការផ្ទេរគ្រាប់មីន ប្រឆាំងមនុស្សជាតិនិងការបំផ្លាញចោល របស់អង្គការសហប្រជាជាតិ។

ការវិភាគ "ភាពខ្លាំង ភាពទន់ខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង" (SWOT) នៃស្ថានភាពពិការភាពនៅកម្ពុជា បានធ្វើឡើងតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើនរួមមាន ស្ថាប័នរដ្ឋ សង្គមស៊ីវិល ដៃគូអភិវឌ្ឍ ផ្នែកឯកជន និងជនពិការ។ លទ្ធផលពីការវិភាគ SWOT ដូចមានបង្ហាញជូន ខាងក្រោម បានយកមកពិចារណាបន្ថែមក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រជាតិដូចខាងក្រោមនេះ។

*ភាពខ្លាំង*

- មានច្បាប់ជាតិស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិជនពិការ
- បានចូលរួមអនុម័តយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត"
- មានកំណើនការយល់ដឹងអំពីពិការភាព
- មានភាពហ៊ានមុខរបស់អង្គការជនពិការនិងក្រុមជួយខ្លួនឯង។

*ភាពទន់ខ្សោយ*

- ការផ្សព្វផ្សាយច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅមិនទាន់បានទូលំទូលាយ
- ការជំរុញការអនុវត្តគោលនយោបាយ ច្បាប់ ផែនការជាតិ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្មនៅមានកម្រិត
- កង្វះខាតធនធានមនុស្ស
- ធនធានហិរញ្ញវត្ថុមានកម្រិត
- នីតិវិធីសម្រាប់បញ្ជ្រាបវិស័យពិការភាពទៅក្នុងផែនការអភិវឌ្ឍជាតិនិងថ្នាក់ក្រោមជាតិនៅមិនទាន់ច្បាស់លាស់
- ការរើសអើងចំពោះជនពិការត្រូវបានកត់សម្គាល់ឃើញ
- កិច្ចសហប្រតិបត្តិការរវាងសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យពិការភាពនៅមានកម្រិត
- ពុំទាន់មានប្រព័ន្ធគ្រប់គ្រងទិន្នន័យជនពិការ និងការធ្វើបច្ចុប្បន្នកម្មលើទិន្នន័យជនពិការនៅមិនទាន់គ្រប់គ្រាន់និងជាក់លាក់។

*កាលានុវត្តភាព*

- ព្រះរាជាណាចក្រកម្ពុជាមានឆន្ទៈក្នុងការការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ដៃគូអភិវឌ្ឍក្នុងនិងក្រៅស្រុកគាំទ្ររាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាពិការភាព
- ព្រះរាជាណាចក្រកម្ពុជាមានគោលនយោបាយច្បាប់ បទបញ្ញា និងប្រកាសពាក់ព័ន្ធពិការភាព
- កម្មវិធីស្តារលទ្ធភាពពលកម្ម និងកម្មវិធីអភិវឌ្ឍន៍ជនពិការត្រូវបានបង្កើតឡើង

- យន្តការសម្របសម្រួលថ្នាក់ជាតិលើវិស័យពិការភាព ដែលមានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិត្រូវបានរៀបចំ
- មូលនិធិជនពិការនិងរដ្ឋបាលសិទ្ធិជនពិការត្រូវបានបង្កើត
- បណ្តាញពិការភាពក្នុងតំបន់និងពិភពលោក
- ការទទួលបានព័ត៌មានទំនើបនិងបច្ចេកវិទ្យាទំនាក់ទំនង អាចជួយអ្នកផ្តល់សេវាកម្ម ក៏ដូចជាជនពិការ។

*ការគំរាមកំហែង*

- ផលប៉ះពាល់ដោយគ្រោះថ្នាក់ចរាចរណ៍ មីន សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម គ្រោះមហន្តរាយដោយគ្រោះទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត ជំងឺមិនឆ្លង និងគ្រោះថ្នាក់ផ្សេងៗ
- សមត្ថភាពនៅមានកម្រិតសម្រាប់ឆ្លើយតបទៅនឹងបញ្ហាពិការភាព
- ការយល់ដឹងកម្រិតទាបអំពីបញ្ហាពិការភាព
- ជនពិការភាគច្រើនមានចំណេះដឹងទាប។

*ស្ថាប័នសម្របសម្រួលការងារពិការភាព*

ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាយន្តការសម្របសម្រួលថ្នាក់ជាតិនិងពិគ្រោះយោបល់លើបញ្ហាពិការភាពតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដោយមានភារកិច្ចក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពទាក់ទងនឹងពិការភាព និងមានភារកិច្ចជំរុញការអនុវត្ត តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព។

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស និងមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន ព្រមទាំងមានអនុប្រធានចំនួន០៦រូប និងមានសមាជិកមកពីតាមបណ្តាក្រសួង ស្ថាប័ន តំណាងអង្គការជនពិការដែលជាជនពិការ តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យពិការភាព តំណាងនិយោជក និងអភិបាលរងនៃគណៈអភិបាលរាជធានី ខេត្តនីមួយៗសរុបចំនួនទាំងអស់៥៨រូប។

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានតួនាទីនិងភារកិច្ចក្នុងការផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងស្តារលទ្ធភាពពលកម្ម ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធនឹងពិការភាព និងស្តារលទ្ធភាពពលកម្ម ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម លើកសំណើកែសម្រួលនឹងបញ្ហាពិការភាព តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធ កៀរគរប្រភពធនធានទាំងក្នុង ទាំងក្រៅប្រទេស រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត រៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព

ដឹកនាំ ចាត់ចែង អនុវត្ត និងធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ រៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការជូនរាជរដ្ឋាភិបាល និងបំពេញភារកិច្ចផ្សេងៗទៀតដែលរដ្ឋាភិបាលប្រគល់ជូន។

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិដែលមានរចនាសម្ព័ន្ធគ្រប់គ្រងចំនួន០៥ផ្នែក។

ក្រុមប្រឹក្សាសកម្មភាពជនពិការ នៅថ្នាក់រាជធានី ខេត្ត និងក្រុមការងារសកម្មភាពជនពិការ នៅតាមក្រសួង ស្ថាប័នមានតួនាទីនិងភារកិច្ចសម្របសម្រួលឱ្យបានអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការដូចបានចែងនៅផ្នែកខាងលើ ។

**មូលនិធិជនពិការ** គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខនស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ដោយមានភារកិច្ចក្នុងការផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការដូចជាផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារឱ្យធ្វើ។

មូលនិធិជនពិការក៏ជាគ្រឹះស្ថានលើកកម្ពស់និងបង្កើនសុខុមាលភាពរបស់ជនពិការ ជាពិសេសជនពិការក្រីក្រ និងយោធិនពិការដែលមិនបានទទួលសេវាស្តារលទ្ធភាពពលកម្មគ្រួសារជនពិការក្រីក្រដែលពឹងផ្អែកលើជនពិការក្នុងជីវភាពរស់នៅ និងយោធិនពិការដែលបានទទួលសេវាស្តារលទ្ធភាពពលកម្ម ឬជនពិការដែលមានជំនាញ តែពុំទាន់ទទួលបានការងារធ្វើ។

មូលនិធិជនពិការមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ប្រាក់កម្ចីសម្រាប់ការសម្របសម្រួលសមស្រប។

**រដ្ឋបាលសិទ្ធិជនពិការ** បច្ចុប្បន្នគឺជាអង្គភាពចំណុះនាយកដ្ឋានសុខុមាលភាពជនពិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានភារកិច្ចផ្សព្វផ្សាយគោលនយោបាយ ច្បាប់ជាតិ អនុសញ្ញា អន្តរជាតិស្តីពីសិទ្ធិជនពិការ ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្របសម្រួលលើកទឹកចិត្តដល់ជនពិការ ក្រសួងស្ថាប័ននិយោជកនិងគ្រឹះស្ថាននានាឱ្យអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័ន និងនីតិបុគ្គលស្របតាមច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនពិការ ក្រសួងស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជនព្រមទាំង អង្គការពាក់ព័ន្ធនានា ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ជួយដោះស្រាយវិវាទផ្សេងៗដែលកើតឡើងក្រោមក្របខ័ណ្ឌនៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងចាត់វិធានការពិន័យអន្តរការណ៍តាមមាត្រា៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការចំពោះក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជន ដែលខកខានមិនបានបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។/៕

## ៥.៣. ទិសដៅជាយុទ្ធសាស្ត្រ

**ទិសដៅជាយុទ្ធសាស្ត្រទី១** : កាត់បន្ថយភាពក្រីក្ររបស់ជនពិការ តាមរយៈការលើកកម្ពស់កំណើនការងារ និងអាជីពសមស្របសម្រាប់ជនពិការ ដើម្បីបង្កើនជីវភាពរស់នៅសមរម្យ និងពង្រឹងភាពជាម្ចាស់ការ

**យុទ្ធសាស្ត្រ**

១.១. ជំរុញក្រសួងស្ថាប័នមានសមត្ថកិច្ច រៀបចំគោលនយោបាយ និងរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីជួយដល់ជនពិការ ពិសេសត្រូវរៀបចំឲ្យជនពិការទទួលបានជំនួយពីរដ្ឋតាមរយៈខ្ទង់ចំណាយលើផ្នែកពិការភាព។

១.២. ជំរុញក្រសួង ស្ថាប័នមានសមត្ថកិច្ច ផ្តល់សេវាគាំទ្រការរស់នៅកន្លែងស្នាក់អាស្រ័យ និងសេវាគាំទ្រសហគមន៍ផ្សេងៗរួមទាំងជំនួយបុគ្គល ដែលចាំបាច់គាំទ្រការរស់នៅនិងការបញ្ចូលជនពិការទៅក្នុងសហគមន៍ បង្ការពីភាពឯកោ ឬឃ្លាតឆ្ងាយពីសហគមន៍។

១.៣. លើកកម្ពស់សិទ្ធិរបស់ជនពិការ ដើម្បីធានាដល់ជីវភាពសមរម្យរបស់ជនពិការ និងសម្រាប់ក្រុមគ្រួសារជនពិការ រួមទាំងអាហារហូបចុកគ្រប់គ្រាន់ មានសម្លៀកបំពាក់និងផ្ទះសម្បែងសមរម្យនិងការកែលម្អជីវភាពរស់នៅប្រចាំថ្ងៃ ដោយគ្មានការរើសអើងនិងឈរលើមូលដ្ឋានពិការភាព។

១.៤. លើកកម្ពស់សិទ្ធិរបស់ជនពិការ ដើម្បីទទួលបានកិច្ចការពារសង្គមដោយគ្មានការរើសអើងឈរលើមូលដ្ឋានពិការភាព និងការពារ ព្រមទាំងជំរុញដល់ការធ្វើឲ្យសម្រេចបាននូវសិទ្ធិស្មើភាពនូវសេវាកម្មទឹកស្អាតនិងធានាដល់ជនពិការឲ្យទទួលបាននូវសេវាកម្ម គ្រឿងឧបករណ៍ និងជំនួយផ្សេងៗដែលសមស្រប និងមានតម្លៃសមរម្យសម្រាប់បម្រើសេចក្តីត្រូវការពាក់ព័ន្ធនឹងពិការភាព។

១.៥. ជំរុញជនពិការ ជាពិសេសស្ត្រី និងកុមារពិការ និងមនុស្សចាស់ពិការឲ្យទទួលបាននូវកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកម្មវិធីការពារសង្គម។

១.៦. ជំរុញដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ជួយជនពិការ និងក្រុមគ្រួសាររបស់គេដែលកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ ឲ្យទទួលបាននូវជំនួយឧបត្ថម្ភពីរដ្ឋ តាមរយៈខ្ទង់ចំណាយលើផ្នែកពិការភាព រួមទាំងការបណ្តុះបណ្តាល ការផ្តល់ប្រឹក្សា ជំនួយហិរញ្ញវត្ថុ និងការថែទាំគ្រប់គ្រាន់ក្នុងអំឡុងពេលសម្រាក។

១.៧. លើកទឹកចិត្តដល់ជនពិការក្នុងការបង្កើតមុខរបរផ្ទាល់ខ្លួនដូចជា កសិមុខរបរ មុខរបរផ្លាតក្មួចផ្លាតមធ្យម ខ្នាតធំ ជាលក្ខណៈឯកត្តជន ឬសមូហភាពរបស់ជនពិការតាមរយៈការផ្តល់ឥណទានដែលមានការប្រាក់ទាបឬគ្មានការប្រាក់ និងសម្ភារសម្រាប់ប្រកបមុខរបរ ឬតាមរយៈការកាត់បន្ថយពន្ធដារនិងការផ្តល់អាទិភាពផ្សេងទៀតស្របតាមច្បាប់ជាធរមាន។

១.៨. បង្កើនកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារផ្សព្វផ្សាយព័ត៌មាន និងបង្កើនការផ្សព្វផ្សាយព័ត៌មានស្តីពីឱកាសការងារឲ្យបានទូលាយដល់ជនពិការតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

១.៩. បង្កើនការផ្តល់អាទិភាពការងារនិងបង្កលក្ខណៈសមស្របសម្រាប់ជនពិការ ក្នុងការទទួលបានការងារ តាមរយៈការជំរុញការអនុវត្តអនុក្រឹត្យស្តីពីការកំណត់អត្រាជនពិការចូលបម្រើការងារតាមក្រសួង ស្ថាប័ន។

១.១០. បង្កើនលទ្ធភាពឲ្យជនពិការបានចូលបំពេញការងារស្ម័គ្រចិត្តដើម្បីទទួលបានបទពិសោធនៅក្នុងទីផ្សារការងារសេរី។

១.១១. លើកទឹកចិត្តផ្នែកពន្ធដារនិងលើកទឹកចិត្តផ្សេងៗទៀតស្របតាមច្បាប់ជាធរមានដល់និយោជក គ្រឹះស្ថានសិក្សា គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលបានទទួលជនពិការឲ្យចូលធ្វើការអប់រំ បណ្តុះបណ្តាលទៅតាមអត្រាកំណត់។

១.១២. ជំរុញការស្តារលទ្ធភាពពលកម្មជំនាញនិងវិជ្ជាជីវៈ ការរក្សាការងារ និងកម្មវិធីនានាដែលជួយឲ្យជនពិការអាចត្រឡប់ចូលបម្រើការងារវិញ។

**ស្ថាប័នទទួលខុសត្រូវ**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងព័ត៌មាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងទេសចរណ៍
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍវិស័យកសិកម្មនិងជនបទ
- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បេឡាជាតិសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- មូលនិធិជនពិការ
- ទីភ្នាក់ងារជាតិមុខរបរនិងការងារ
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី២ : ផ្តល់ដល់ជនពិការនូវសេវាសុខភាពប្រកបដោយគុណភាពនិងសមធម៌ ព្រមទាំងការស្តារលទ្ធភាពពលកម្មកាយសម្បទានិងសតិបញ្ញា**

**យុទ្ធសាស្ត្រ**

២.១. បង្កើនចំនួនអ្នកជំនាញផ្នែកសុខភាពនិងស្តារលទ្ធភាពពលកម្ម តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសបឋម បណ្តុះបណ្តាលបន្ត និងជំរុញលទ្ធភាពចំណេះដឹងនៃការប្រើប្រាស់ឧបករណ៍ជំនួយ ទ្រទ្រង់រាងកាយ និងបញ្ចូលផ្នែកនេះឲ្យមាននៅគ្រប់មន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិកឯកជន មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មដើម្បីព្យាបាលអ្នកជំងឺកុំឲ្យធ្លាក់ខ្លួនពិការ។

២.២. បង្កើនការជួយបណ្តុះបណ្តាលគ្រួសារដែលមានសមាជិកពិការ ជនពិការ និងអ្នកស្ម័គ្រចិត្ត អំពីវិធីថែទាំ និងបច្ចេកទេសស្តារលទ្ធភាពពលកម្មតាមប្រភេទពិការនីមួយៗ ដើម្បីឲ្យគ្រួសារដែលមានសមាជិកពិការ ជនពិការ មានលទ្ធភាពស្តារកាយសម្បទានិងសតិបញ្ញាជនពិការ។

២.៣. ពង្រឹងនិងពង្រីកសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា តាមសហគមន៍ សេវាពិគ្រោះយោបល់ ព្យាបាលជំងឺផ្លូវចិត្ត និងសតិបញ្ញាខ្សោយសម្រាប់ជួយដល់ជនពិការ។

២.៤. ជំរុញការអនុវត្តរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។

២.៥. បង្កើនកម្មវិធីបង្ការពិការភាពដល់ពលរដ្ឋគ្រប់រូប តាមរយៈការថែទាំសុខភាពក្នុងពេលមានគភ៌ ការតាមដាន និងការវិនិច្ឆ័យរោគដែលនាំឲ្យមានពិការភាពទាន់ពេលវេលា ការផ្តល់ថ្នាំបង្ការជំងឺដែលនាំឲ្យមានពិការភាព ការផ្តល់អាហារទ្រទ្រង់រាងកាយ ការអប់រំអំពីមូលហេតុដែលនាំឲ្យពិការភាព និងការព្យាបាលតាមវិធីវេជ្ជសាស្ត្រនិងការអប់រំកាយសម្បទាឡើងវិញឲ្យទាន់ពេលវេលា។

២.៦. ជំរុញការផ្តល់របបគោលនយោបាយចំពោះជនពិការ ដែលមានពិការភាពធ្ងន់ធ្ងរនិងក្រីក្រ និងជនពិការដែលក្រីក្របំផុតគ្មានទីពឹងដើម្បីទទួលបានការផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់រដ្ឋ រួមបញ្ចូលទាំងការផ្តល់ប្រាក់សម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្ម ការផ្តល់ឧបត្ថម្ភថវិកា និងប្រាក់សោហ៊ុយធ្វើដំណើរមកទទួលសេវានៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម។

**ស្ថាប័នទទួលខុសត្រូវ**

- ក្រសួងសុខាភិបាល

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មូលនិធិជនពិការ
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា
- មណ្ឌលសុខភាព មន្ទីរពេទ្យ
- អ្នកផ្តល់សេវាសុខភាព
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី៣ : បង្កើនកិច្ចអន្តរាគមន៍សេវាយុត្តិធម៌ កាត់បន្ថយ និងឈានទៅរកការលុបបំបាត់ការរើសអើង ការរំលោភបំពាន ការប្រមាថ និងការកេងប្រវ័ញ្ចលើជនពិការ**

យុទ្ធសាស្ត្រ

៣.១. បង្កើនការផ្សព្វផ្សាយអំពីបញ្ហាពិការភាពទៅដល់ប្រជាពលរដ្ឋដើម្បីយល់ដឹងអំពីសក្តានុពលរបស់ជនពិការ។

៣.២. លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ សេរីភាព និងសន្តិសុខបុគ្គលរបស់ជនពិការឱ្យមានលក្ខណៈស្មើភាពជាមួយមនុស្សដទៃទៀតតាមរយៈការផ្សព្វផ្សាយគោលនយោបាយ ច្បាប់ ផែនការជាតិ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព។

៣.៣. ពង្រឹងយន្តការសម្របសម្រួលសម្រាប់ជួយដល់ជនពិការ ដើម្បីទទួលបានសិទ្ធិសេរីភាពចាកផុតពីការធ្វើទារុណកម្មឬអំពើឃោរឃៅ យង់ឃ្នងនិងអមនុស្សធម៌ អាប់ឱនកិត្តិយស និងការដាក់ទណ្ឌកម្ម ពិសេសលើស្ត្រីនិងកុមារពិការ។

៣.៤. ជំរុញការបណ្តុះបណ្តាលដល់អ្នកដែលកំពុងបម្រើការងារនៅក្នុងវិស័យយុត្តិធម៌ដើម្បីជួយធានាពីសិទ្ធិទទួលបានសេវាយុត្តិធម៌ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការ។

៣.៥. បង្កើនការដាក់វិធានការតាមផ្លូវច្បាប់ ផ្លូវរដ្ឋបាល ឬវិធានការដទៃទៀតឱ្យមានប្រសិទ្ធភាព ដើម្បីការពារជនពិការឱ្យរួចផុតពីការធ្វើបាប ឬអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬការដាក់ទារុណកម្ម ដោយឈរលើមូលដ្ឋានមួយស្មើភាពគ្នាជាមួយអ្នកដទៃ។

៣.៦. ធានាឱ្យជនពិការមានសិទ្ធិស្មើគ្នា ក្នុងការធ្វើជាម្ចាស់លើទ្រព្យសម្បត្តិ ឬទទួលមរតក គ្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុផ្ទាល់ខ្លួនផ្សេងៗ និងមានសិទ្ធិស្មើគ្នាចំពោះការខ្ចីឥណទាន។

ធនាគារ ការបញ្ចាំ និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ ហើយត្រូវធានាថាជនពិការមិនត្រូវបានគេដកហូតយកទ្រព្យសម្បត្តិរបស់ពួកគេតាមអំពើចិត្តនោះទេ។

៣.៧. លើកកម្ពស់សិទ្ធិទទួលបានសេវាយុត្តិធម៌ ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត តាមរយៈបទប្បញ្ញត្តិនៃដំណោះស្រាយសមស្របតាមអាយុ និងតាមនីតិវិធី ដើម្បីជួយសម្រួលតួនាទីដ៏មានប្រសិទ្ធភាពរបស់ពួកគេ ទោះក្នុងនាមជាអ្នកចូលរួមដោយផ្ទាល់ឬដោយប្រយោលក្តី រួមទាំងធ្វើជាសាក្សីនៅរាល់ចំណាត់ការរឿងក្តីនៅដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលដំបូងផ្សេងៗទៀត។

៣.៨. ពង្រឹងសិទ្ធិទទួលបានសេវាយុត្តិធម៌ដែលមានប្រសិទ្ធភាពសម្រាប់ជនពិការ ត្រូវជំរុញការបណ្តុះបណ្តាលឱ្យបានសមស្របដល់អ្នកទាំងឡាយដែលកំពុងបម្រើការងារនៅក្នុងវិស័យយុត្តិធម៌ រួមទាំងនគរបាល បុគ្គលិកពន្ធនាគារ និងទទួលបានមេធាវីដោយឥតគិតថ្លៃ។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងយុត្តិធម៌
- ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- អង្គបាលសិទ្ធិជនពិការ
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ទិសដៅជាយុទ្ធសាស្ត្រទី៤ : ពង្រឹងនិងពង្រីកសេរីភាព សន្តិសុខបុគ្គល និងការគ្រប់គ្រងស្ថានភាពនៃហានិភ័យ ស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌ ក្នុងពេលមានគ្រោះមហន្តរាយដែលរួមបញ្ចូលជនពិការ

យុទ្ធសាស្ត្រ

៤.១. ការពារមិនឱ្យមានការដកហូតសេរីភាពរបស់ជនពិការ ដោយខុសច្បាប់ឬតាមអំពើចិត្ត ដោយធានាថាការដកហូតសេរីភាពណាមួយត្រូវតែអនុលោមទៅតាមច្បាប់ និងនីតិវិធី

គ្មានការដកហូតសេរីភាព ដោយសម្អាងលើពិការភាព ទោះក្នុងករណីណាក៏ដោយត្រូវឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

៤.២. បង្កើនកិច្ចការពារនិងសុវត្ថិភាពរបស់ជនពិការ ក្នុងស្ថានភាពនៃហានិភ័យ រួមទាំងជម្លោះប្រដាប់អាវុធស្ថានភាពបន្ទាន់ផ្នែកមនុស្សធម៌ និងការកើតឡើងនូវគ្រោះមហន្តរាយពីធម្មជាតិ។

៤.៣. លើកកម្ពស់សេវានិងកម្មវិធី ដែលរួមមានទាំងសម្រាប់ជំនួយផ្ទាល់ និងសេវាប្រឹក្សាមិត្តដែលជួយទ្រទ្រង់ដល់ជនពិការ ជាពិសេសជនពិការច្រើនប្រភេទ ពិការធ្ងន់ធ្ងរ និងពិការផ្សេងៗ ក្នុងការរស់នៅដោយឯករាជ្យ។

៤.៤. បណ្តុះបណ្តាលការដាក់បញ្ចូលបញ្ហាពិការភាព សម្រាប់បុគ្គលិកពាក់ព័ន្ធទាំងអស់ ដើម្បីពង្រឹងនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដោយដាក់បញ្ចូលជនពិការ។

៤.៥. បង្កើនឧបករណ៍និងបច្ចេកវិទ្យាជំនួយសម្រាប់ជនពិការ ដើម្បីជួយក្នុងគ្រាមានគ្រោះមហន្តរាយ។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- កាកបាទក្រហមកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- ក្រសួងធនធានទឹកនិងឧតុនិយម
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់តំបន់
- គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់រាជធានី ខេត្ត
- ដៃគូអភិវឌ្ឍន៍
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ទិសដៅជាយុទ្ធសាស្ត្រទី៥ : ធានាថាជនពិការអាចមានលទ្ធភាពទទួលបានសេវាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកបដោយគុណភាពនិងសមភាព។

យុទ្ធសាស្ត្រ

៥.១. បង្កើនអត្រាការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា និងថ្នាក់អនុវិទ្យាល័យរវាងកុមារពិការ និងកុមារមិនពិការ។

៥.២. រៀបចំនិងបង្កើនសម្ភារៈសិក្សា និងអក្សរសញ្ញា ក្នុងទម្រង់ដែលអាចប្រើប្រាស់បានសម្រាប់សិស្សពិការ។

៥.៣. បង្កើនការបង្រៀនជំនាញអភិវឌ្ឍន៍សង្គមនិងបំណិនជីវិត ដើម្បីជួយដល់ជនពិការបានចូលរួមដោយស្មើភាពនិងយ៉ាងពេញលេញក្នុងការអប់រំ និងជាសមាជិកក្នុងសហគមន៍។

៥.៤. លើកកម្ពស់ការអប់រំសម្រាប់ជនពិការ ជាពិសេសកុមារដែលពិការភ្នែក ៖ ថ្លង់ ត្រូវបានធ្វើឡើងក្នុងទម្រង់និងភាសា មធ្យោបាយ ទំនាក់ទំនងសម្រាប់ជនពិការម្នាក់ៗ ឲ្យសមស្របបំផុត ក្នុងបរិយាកាសបង្កើនការអភិវឌ្ឍសង្គម និងការសិក្សាធិការជាអតិបរមា។

៥.៥. លើកទឹកចិត្តនិងបង្កើនចំនួនគ្រូ រួមទាំងគ្រូពិការដែលមានសមត្ថភាពក្នុងការបង្រៀនភាសាសញ្ញា អក្សរស្ទាប និងបណ្តុះបណ្តាលដល់អ្នកជំនាញ បុគ្គលិកដែលធ្វើការនៅគ្រប់កម្រិតសិក្សា។

៥.៦. លើកកម្ពស់ដល់ជនពិការទទួលបានការអប់រំថ្នាក់ឧត្តមសិក្សាជាទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំមនុស្សពេញវ័យ និងការសិក្សាពេញមួយជីវិត ដោយគ្មានការរើសអើង និងឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

៥.៧. ជំរុញឲ្យមានការសម្របសម្រួលសមស្របសម្រាប់ជនពិការ ដើម្បីទទួលបាននូវការអប់រំប្រកបដោយគុណភាព។

៥.៨. ជំរុញឲ្យមានការដាក់បញ្ចូលកម្មវិធីសិក្សាសម្រាប់ការអប់រំ រួមមាន មាតិកា មេរៀន និងឥរិយាបថវិជ្ជមានចំពោះជនពិការនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។

៥.៩. បង្កើនការផ្តល់អាហាររូបករណ៍សម្រាប់សិស្សនិងនិស្សិតពិការ ដើម្បីបន្តការសិក្សាទៅថ្នាក់ឧត្តមសិក្សាគ្រប់កម្រិត។

៥.១០. ផ្តល់ឱកាសក្នុងការអភិវឌ្ឍនិងប្រើប្រាស់សក្តានុពលខាងបញ្ញា សិល្បៈ និងគំនិតច្នៃប្រឌិតរបស់ជនពិការ មិនត្រឹមតែដើម្បីផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះទេ តែមទាំងដើម្បីភាពសម្បូរបែបរបស់សង្គមទៀតផង។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាសកម្មភាពជនពិការ/

- ដៃគូរអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី៦ : លើកកម្ពស់ការចូលរួមរបស់ជនពិការក្នុងការសម្តែងមតិ ទទួលព័ត៌មាន និងចូលរួមជីវភាពនយោបាយ**

**យុទ្ធសាស្ត្រ**

៦.១. ជំរុញជនពិការគ្រប់រូបចូលរួមក្នុងការបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការបោះឆ្នោត តាមរយៈការផ្សព្វផ្សាយ អប់រំ និងលើកទឹកចិត្តដល់ជនពិការ។

៦.២. លើកទឹកចិត្តនិងបង្កើនការចូលរួមរបស់ជនពិការយ៉ាងពេញលេញ ក្នុងជីវភាពនយោបាយ និងសាធារណៈដោយផ្ទាល់ឬតាមរយៈអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយសេរី ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងសិទ្ធិនិងឱកាសផ្សេងៗនៃជំនួយដល់ការរស់នៅសម្រាប់ជនពិការក្នុងការបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត។

៦.៣. ធានាថានីតិវិធី មធ្យោបាយសម្ភារបរិក្ខា និងសម្ភារៈបោះឆ្នោតមានលក្ខណៈសមស្របអាចទទួលយកបាន ងាយយល់ និងងាយប្រើប្រាស់។

៦.៤. ធានាការពារសិទ្ធិរបស់ជនពិការក្នុងការបោះឆ្នោតដោយសម្ងាត់ និងក្នុងការធ្វើប្រជាមតិជាសាធារណៈ ដោយគ្មានការបំភិតបំភ័យ និងក្នុងការឈរឈ្មោះបោះឆ្នោតដើម្បីទទួលកាន់មុខតំណែង និងបំពេញគ្រប់មុខងារសាធារណៈឱ្យមានប្រសិទ្ធភាពនៅគ្រប់ជាន់ថ្នាក់នៃស្ថាប័នរដ្ឋាភិបាល ដោយជួយសម្រួលដល់ការប្រើប្រាស់បច្ចេកវិទ្យាជំនួយថ្មីៗដែលសមស្រប។

៦.៥. ធានាដល់ជនពិការនូវការសម្តែងឆន្ទៈដោយសេរីក្នុងឋានៈជាអ្នកបោះឆ្នោត ហើយដើម្បីសម្រេចគោលដៅនេះ ក្នុងករណីចាំបាច់និងតាមសំណើរបស់ជនពិការ អនុញ្ញាតឱ្យមានការជួយក្នុងការបោះឆ្នោតជំនួសដោយអ្នកណាម្នាក់តាមការជ្រើសរើសរបស់ពួកគេ។

៦.៦. ជំរុញយ៉ាងសកម្មឱ្យមានបរិយាកាសមួយ ដែលជនពិការអាចចូលរួមយ៉ាងពេញលេញ និងជាក់ស្តែងក្នុងដំណើរការកិច្ចការសាធារណៈដោយគ្មានការរើសអើង និងដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ ព្រមទាំងលើកទឹកចិត្តឱ្យពួកគេចូលរួមក្នុងកិច្ចការសាធារណៈ។

៦.៧. ជំរុញការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនិងសមាគមនានាដែលពាក់ព័ន្ធនឹងជីវភាពនយោបាយជីវភាពសាធារណៈរបស់ប្រទេស និងក្នុងសកម្មភាពដែលជាប្រឹក្សារបស់គណបក្សនយោបាយនានា។

៦.៤. លើកទឹកចិត្តក្នុងការបង្កើតនិងការចូលរួមក្នុងអង្គការជនពិការនានា ដើម្បីធ្វើជាអ្នកតំណាងជនពិការនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅលើឆាកអន្តរជាតិ។

៦.៥. ធានាថាជនពិការអាចអនុវត្តសិទ្ធិបង្កើតសហជីព ដោយឈរលើមូលដ្ឋានស្មើភាពជាមួយអ្នកដទៃ។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងព័ត៌មាន
- ក្រសួងអភិវឌ្ឍន៍ជនបទ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ទិសដៅជាយុទ្ធសាស្ត្រទី៧ : ធានាដល់ការចូលរួមសកម្មភាពសង្គមរួមមាន វប្បធម៌ សាសនា កីឡា សិល្បៈ ការសម្រាកលំហែ និងសកម្មភាពផ្សេងៗទៀត

យុទ្ធសាស្ត្រ

៧.១. លើកកម្ពស់ការទទួលបានឧបករណ៍និងសម្ភារៈផ្សេងៗ ក្នុងវិស័យវប្បធម៌តាមទម្រង់ក្រាយដែលជនពិការអាចទទួលបាន និងមានកម្មវិធីទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗក្នុងទម្រង់ក្រាយដែលជនពិការអាចទទួលបាន។

៧.២. បង្កើនឱកាសដល់ជនពិការក្នុងការរៀបចំ ចាត់ចែង អភិវឌ្ឍ និងចូលរួមជាសាធារណៈនៅគ្រប់កម្រិតក្នុងសកម្មភាពវប្បធម៌ សាសនា សិល្បៈ កីឡា និងកម្សាន្ត ពិសេសសម្រាប់ជនពិការ តាមរយៈការផ្តល់ការណែនាំ ការបណ្តុះបណ្តាល និងធនធានសមស្របដែលផ្អែកលើគោលការណ៍ស្មើភាពជាមួយអ្នកដទៃទៀត។

៧.៣. បង្កើនឱកាសសម្រាប់កុមារពិការទទួលបានសិទ្ធិស្មើភាពគ្នាជាមួយកុមារផ្សេងទៀត ក្នុងការចូលរួមលេងកម្សាន្ត ការសម្តែង ការលំហែ រួមទាំងសកម្មភាពទាំងឡាយនៅក្នុងកម្មវិធីសាលារៀន តាមរយៈបង្កើនការយល់ដឹងអំពីការដាក់បញ្ចូលពិការភាព។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងព័ត៌មាន
- ក្រសួងធម្មការ និងសាសនា
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី៨ : អភិវឌ្ឍ និងកែសម្រួលឲ្យមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់បរិស្ថានរូបវន្តមធ្យោបាយដឹកជញ្ជូនបម្រើជាសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនងចំពោះជនពិការ**

យុទ្ធសាស្ត្រ

៨.១. ជំរុញឲ្យមានបទដ្ឋានស្តង់ដាស្តីពីការសាងសង់សំណង់អគារដែលបម្រើជាសាធារណៈរួមមានកន្លែងសាសនា ផ្សារ មន្ទីរពេទ្យ មណ្ឌលសុខភាព កន្លែងកម្សាន្ត ចំណតសាធារណៈ បង្គន់សាធារណៈ និងឧបករណ៍ដែលត្រូវបានកែសម្រួលសម្រាប់បង្កលក្ខណៈងាយស្រួលដល់ជនពិការ។

៨.២. លើកកម្ពស់ការយល់ដឹងអំពីលក្ខណៈសម្របសម្រួលសមស្របរបស់ជនពិការដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបន្ទុកផ្នែកផលិត សាងសង់ ជំរឿងជាដើម ដើម្បីឲ្យជនពិការអាចប្រើប្រាស់បាន។

៨.៣. ជំរុញការអនុវត្តជាមួយក្រសួងមានសមត្ថកិច្ច ដែលផ្តល់លិខិតអនុញ្ញាតលើគម្រោងសាងសង់ ការសាងសង់ និងត្រួតពិនិត្យសំណង់ ទីកន្លែងដែលបម្រើជាសាធារណៈក្នុងការធានាលទ្ធភាពងាយស្រួលចេញចូលសម្រាប់ជនពិការ។

៨.៤. ជំរុញគ្រប់ប្រព័ន្ធដឹកជញ្ជូនដែលបម្រើជាសាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនពិការអាចប្រើបាន។

៨.៥. បង្កើនការផ្តល់បណ្ណបើកបរនិងការប្រើប្រាស់ផ្លាកសញ្ញាអាទិភាពរបស់ជនពិការ។

៨.៦. បង្កើនការបកប្រែជាភាសាសញ្ញា សំឡេង អក្សរធំ អក្សរស្ទាប នៅតាមប្រព័ន្ធផ្សព្វផ្សាយ រួមទាំងអ្នកផ្តល់ព័ត៌មានតាមរយៈប្រព័ន្ធអ៊ិនធឺណិត ដើម្បីធ្វើឱ្យជនពិការអាចទទួលយកសេវាកម្មទាំងនោះបាន។

៨.៧. បង្កើតឱ្យមានភាសាសញ្ញាតែមួយប្រភេទសម្រាប់ប្រទេសកម្ពុជា។

៨.៨. បង្កើនចំនួនអ្នកបកប្រែភាសាសញ្ញានិងការបោះពុម្ពជាអក្សរធំនិងអក្សរស្ទាប។

៨.៩. បង្កលក្ខណៈទីកន្លែងសម្រាប់ការសម្តែងឬសេវាកម្មវប្បធម៌ដូចជា រោងល្ខោន សារមន្ទីរ រោងភាពយន្ត បណ្ណាល័យ និងសេវាកម្មទេសចរណ៍ ព្រមទាំងបង្កលទ្ធភាពដែលអាចប្រើប្រាស់បានសម្រាប់ជនពិការចូលដល់បូជនីយដ្ឋាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិ។

៨.១០. បង្កើនការផ្តល់ព័ត៌មានជាសាធារណៈឱ្យដល់ជនពិការ តាមទម្រង់និងបច្ចេកវិទ្យាដែលពួកគេអាចទទួលបានសមស្របទៅនឹងប្រភេទផ្សេងៗនៃពិការភាព ឱ្យបានទាន់ពេលវេលា និងគ្មានការបង់ប្រាក់បន្ថែម តាមរយៈការផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីពិការភាព។

៨.១១. ជំរុញការទទួលនិងជួយសម្រួលដល់ការប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាប និងទំនាក់ទំនងផ្សេងៗទៀត ព្រមទាំងគ្រប់មធ្យោបាយ របៀប និងទម្រង់នៃទំនាក់ទំនងផ្សេងទៀតដែលអាចទទួលយកបានតាមការជ្រើសរើសរបស់ជនពិការ ក្នុងការទាក់ទងជាផ្លូវការ។

៨.១២. ជំរុញឱ្យបុគ្គលឯកជននានា ដែលផ្តល់សេវាកម្មផ្សេងៗជាសាធារណៈរួមទាំងតាមរយៈអ៊ិនធឺណិតផ្តល់ព័ត៌មាននិងសេវាកម្មផ្សេងៗតាមទម្រង់ដែលជនពិការអាចទទួល និងប្រើប្រាស់បាន។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងព័ត៌មាន
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងធម្មការនិងសាសនា

- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងអប់រំ យុវជន និងកីឡា
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី៩ : ធានាសមភាពយេនឌ័រនិងការលើកកម្ពស់សមត្ថភាពស្ត្រីនិងកុមារពិការ**

យុទ្ធសាស្ត្រ

៩.១. បង្កើនការយកចិត្តទុកដាក់ដល់ស្ត្រីនិងកុមារពិការ ដើម្បីទទួលបានភាពស្មើគ្នានិងពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត តាមរយៈការអនុវត្តគោលនយោបាយផ្សេងៗទាក់ទងនឹងស្ត្រីនិងកុមារពិការ។

៩.២. ជំរុញឲ្យមានអ្នកតំណាងស្ត្រីពិការដែលមានសមត្ថភាពចូលរួមក្នុងការសម្រេចចិត្តនានាក្នុងស្ថាប័នជាតិ និងធ្វើឲ្យស្ត្រីពិការទទួលបានការអភិវឌ្ឍ វឌ្ឍនភាព និងការផ្តល់សិទ្ធិអំណាចឲ្យបានពេញលេញដើម្បីធានាឲ្យពួកគេអនុវត្ត និងទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត តាមរយៈការផ្តល់អាទិភាពដល់ស្ត្រីពិការទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

៩.៣. លើកស្ទួយស្ថានភាពស្ត្រី ពិសេសស្ត្រីពិការ ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ដោយប្រែក្លាយស្ត្រីឲ្យទៅជាកម្លាំងពលករដ៏មានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យតាមរយៈជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា។

៩.៤. ជំរុញនិងលើកកម្ពស់ស្ត្រីនិងយុវតីពិការឲ្យមានសិទ្ធិនិងឱកាសទទួលបានសេវាសុខភាពផ្លូវភេទនិងបន្តពូជនៅលើមូលដ្ឋានសមធម៌មួយជាមួយស្ត្រីនិងយុវតីដែលមិនពិការ។

៩.៥. ធានាដល់ការផ្តល់ប្រាក់បៀវត្សរ៍ចំពោះស្ត្រីពិការបានស្មើគ្នា និងឱកាសការងារដូចគ្នាតាមរយៈការលើកកម្ពស់សិទ្ធិរបស់ស្ត្រី។

៩.៦. ធានាឲ្យកុមារពិការទទួលបានដោយពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយកុមារផ្សេងទៀត។

៩.៧. បង្កើនការចូលរួមគ្រប់សកម្មភាពដែលទាក់ទងនឹងឧត្តមប្រយោជន៍របស់កុមារពិការ។

៩.៨. លើកកម្ពស់ដល់កុមារពិការឲ្យទទួលបានសិទ្ធិបញ្ចេញមតិរបស់ខ្លួនដោយសេរីលើបញ្ហាគ្រប់បែបយ៉ាងដែលប៉ះពាល់ដល់ពួកគេ។ ទស្សនៈរបស់ពួកគេត្រូវទទួលបានការពិចារណាថ្លឹងថ្លែងឲ្យបានសមស្របទៅនឹងអាយុនិងភាពចាស់ទុំរបស់កុមារពិការ ដោយផ្អែកលើ

មូលដ្ឋានសមភាពគ្នាជាមួយបុរសផ្សេងទៀតហើយពួកគេត្រូវទទួលបាននូវការជួយគាំទ្រសមស្របទៅនឹងពិការភាពនិងអាយុដើម្បីទទួលបាននូវសិទ្ធិនេះយ៉ាងពិតប្រាកដ។

**ស្ថាប័នទទួលខុសត្រូវ**

- ក្រសួងកិច្ចការនារី
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- ក្រសួងព័ត៌មាន
- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ក្រសួងធម្មការនិងសាសនា
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ដៃគូអភិវឌ្ឍនានា
- អង្គការមិនមែនរដ្ឋាភិបាល និងក្រុមជួយខ្លួនឯង
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**ទិសដៅជាយុទ្ធសាស្ត្រទី១០ ៈពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយថ្នាក់អន្តរជាតិ ថ្នាក់អន្តរតំបន់ ថ្នាក់តំបន់ ថ្នាក់អនុតំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

យុទ្ធសាស្ត្រ

១០.១. រៀបចំនិងចូលរួមប្រព្រឹត្តិការណ៍ផ្សេងៗស្តីពីពិការភាពនៅថ្នាក់អន្តរជាតិ ថ្នាក់អន្តរតំបន់ ថ្នាក់តំបន់ ថ្នាក់អនុតំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១០.២. ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងកម្មវិធីអភិវឌ្ឍន៍អន្តរជាតិនានាត្រូវមានបញ្ចូលជនពិការហើយជនពិការអាចទទួលយកបាន។

១០.៣. បង្កើនការសម្របសម្រួលនិងការគាំទ្រដល់ការកសាងសមត្ថភាព រួមទាំងតាមរយៈការផ្លាស់ប្តូរ និងការចែករំលែកព័ត៌មាន បទពិសោធ កម្មវិធីបណ្តុះបណ្តាល និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

១០.៤. បង្កើនកិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវ និងការទទួលបានចំណេះដឹង បច្ចេកទេស និងវិទ្យាសាស្ត្រ។

១០.៥. ជំរុញការផ្តល់ជំនួយសេដ្ឋកិច្ចនិងបច្ចេកទេសសមស្រប រួមទាំងការជួយសម្រួលដល់ការទទួលបាននូវបច្ចេកវិទ្យាជំនួយ តាមរយៈការផ្ទេរបច្ចេកវិទ្យា។

១០.៦. ពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីរួមចំណែកជាមួយដៃគូអភិវឌ្ឍព្រមទាំងការផ្តួចផ្តើមកម្មវិធីនានា ដើម្បីគាំទ្រការអនុវត្តកិច្ចព្រមព្រៀង នៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់អនុតំបន់ និងថ្នាក់អន្តរតំបន់។

១០.៧. ពង្រឹងការផ្លាស់ប្តូរបទពិសោធនិងការអនុវត្តល្អក្នុងក្របខណ្ឌអន្តរតំបន់ដែលទាក់ទងនឹងជនពិការ និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀង នៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់អនុតំបន់ និងថ្នាក់អន្តរតំបន់។

១០.៨. បំពេញកាតព្វកិច្ចក្នុងនាមជាប្រទេសសមាជិកហត្ថលេខីឬជាភាគីនៃសន្ធិសញ្ញាផ្សេងៗ។

១០.៩. បង្កើនការសម្របសម្រួលការងារពិការភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

១០.១០. ពង្រឹងនិងពង្រីកបណ្តាញជនពិការនៅថ្នាក់ជាតិនិងអន្តរជាតិ។

ស្ថាប័នទទួលខុសត្រូវ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដៃគូអភិវឌ្ឍនានា
- អាជ្ញាធរពាក់ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ
- ស្ថាប័នធ្វើការងារពាក់ព័ន្ធវិស័យពិការភាពផ្សេងទៀត

## ៦. សមត្ថភាពការងារ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨នេះ ផ្តល់ក្របខ័ណ្ឌគោលការណ៍មួយ សម្រាប់អនុវត្តវិធានការឆ្លើយតបនឹងវិស័យពិការភាព។ ចាំបាច់ត្រូវរៀបចំផែនការសកម្មភាពនិងយន្តការពាក់ព័ន្ធនានា ដូចជាយន្តការហិរញ្ញប្បទាន ក្របខ័ណ្ឌការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងក្របខ័ណ្ឌច្បាប់ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីពិការភាពនេះ និងផ្តល់ជាមូលដ្ឋានរឹងមាំសម្រាប់ការកៀរគរធនធាន។

### *៦.១.ដំណាក់កាលសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨*

ការអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ត្រូវបែងចែកតាមដំណាក់កាលដូចខាងក្រោម៖/.

- នៅដំណាក់កាលទី១ (២០១៤-២០១៥) : យន្តការចាត់ចែងស្ថាប័ននិងហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ត្រូវរៀបចំឡើងមួយឲ្យជាមុនក្រោបខ័ណ្ឌជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ។ នៅក្នុងដំណាក់កាលនេះក្រសួងស្ថាប័នពាក់ព័ន្ធនីមួយៗត្រូវកសាងផែនការសកម្មភាពលម្អិត និងចាត់អាទិភាព(២០១៤-២០១៨) ដែលរួមមានសកម្មភាពជាក់លាក់មួយសម្រាប់ការគ្រប់គ្រងចំណេះដឹងនិងការសម្របសម្រួល។
- នៅដំណាក់កាលទី២ (២០១៥-២០១៦) : ដំណាក់កាលនេះ នឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១ ជាមួយការពង្រីកសកម្មភាពថ្មីទៀតដូចជាការរៀបចំយន្តការទទួលបានមូលនិធិ និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាពការបញ្ជ្រាបពិការភាពនៅគ្រប់កម្រិត តាមវិស័យនានា ការប្រតិបត្តិប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការគ្រប់គ្រងថវិកា និងការចាប់ផ្តើមគម្រោងឬកម្មវិធីនានា ដែលមានអាទិភាពខ្ពស់នៅក្នុងវិស័យសំខាន់ៗ ដូចបានកំណត់នៅក្នុងផែនការសកម្មភាពឆ្លើយតបនឹងពិការភាព។
- នៅដំណាក់កាលទី៣ (២០១៦-២០១៨) : ដំណាក់កាលនេះនឹងបន្តគាំទ្រដល់ការអនុវត្តសកម្មភាពដូចដែលបានគ្រោងក្នុងដំណាក់កាលទី១និងទី២ដោយនឹងត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃពាក់កណ្តាលអាណត្តិនិងជាដំណាក់កាលនៃការប្រមូលព័ត៌មានដើម្បីធ្វើការបូកសរុបនូវវឌ្ឍនភាពនៃផែនការនេះ។ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិមានភារកិច្ចផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពមកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការដើម្បីធ្វើការបូកសរុបរបាយការណ៍ជូនទៅរាជរដ្ឋាភិបាល និងពង្រឹងការអនុវត្តផែនការនេះបន្តរហូតដល់ចប់អាណត្តិ។ ដំណាក់កាលនេះផងដែរ ប្រសិនបើការអនុវត្តមិនទាន់គ្រប់តាមផែនការកំណត់ ត្រូវរៀបចំផែនការពិតដើម្បីឈានទៅសម្រេចផែនការខាងលើនេះឲ្យខាងតែបាន។

**ការចាត់ចែងរចនាសម្ព័ន្ធស្ថាប័ន**

ក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលមានតួនាទីនិងសិទ្ធិអំណាចពេញលេញ ក្នុងការសម្របសម្រួលការងារពិការភាព ហើយមានសមត្ថភាពគ្រប់គ្រាន់និងលក្ខណសម្បត្តិពេញលេញ ដែលបានទទួលស្គាល់ជាផ្លូវការ និងមានសិទ្ធិទទួលយកថវិកាដោយផ្ទាល់ពីគ្រប់ដៃគូអភិវឌ្ឍនានា។

នៅកម្រិតក្រសួង ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន ក៏ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។ ការទទួលខុសត្រូវរបស់ក្រុមការងារនេះ ត្រូវធ្វើឲ្យច្បាស់លាស់នាពេលឆាប់ៗខាងមុខជាពិសេសទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងៗទៀតនៅក្នុងក្រសួងពាក់ព័ន្ធ ដើម្បីធានាថាការរៀបចំគោលនយោបាយ កម្មវិធី និងការវិនិយោគតាមវិស័យ បានគិតគូរពេញលេញពីការដាក់បញ្ចូលជនពិការ។

ក្រុមប្រឹក្សាសកម្មភាពជនពិការនៅថ្នាក់រាជធានី ខេត្ត បានបង្កើតឡើងតាមរយៈអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ។

ក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានី ខេត្ត មានតួនាទីទទួលខុសត្រូវរួមលើការគ្រប់គ្រង និងតាមដានត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់ជាតិ និងការគាំទ្រការងារចាត់ចែងរដ្ឋបាលពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្នុងករណីចាំបាច់។

នៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំអំពីការកសាងអភិវឌ្ឍនៅក្នុងបរិបទនៃការដាក់បញ្ចូលជនពិការនឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងខែកក្កដា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។ គោលការណ៍ទាំងនេះត្រូវផ្អែកលើបទពិសោធជាច្រើន ដែលទទួលបានក្នុងឆ្នាំកន្លងទៅថ្មីៗនេះ តាមរយៈគម្រោងសាកល្បងដែលភាគច្រើនមាននៅថ្នាក់ឃុំ សង្កាត់តាមតែអាចធ្វើបាន គោលការណ៍ណែនាំទាំងនេះនឹងមានរួមបញ្ចូលអនុសាសន៍នានាអំពីកិច្ចសហការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅលំដាប់ខុសៗគ្នា (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) និងជាពិសេសនីតិវិធីសម្រាប់ឱ្យឃុំ សង្កាត់ទទួលបានជំនាញបច្ចេកទេស អំពីពិការភាព ពីការិយាល័យ ឬមន្ទីរនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ឬថ្នាក់រាជធានី ខេត្ត។

**ការកសាងផែនការសកម្មភាព**

ក្រសួងពាក់ព័ន្ធទាំងអស់ ត្រូវបង្កើតផែនការសកម្មភាពជាអាទិភាពរបស់ខ្លួន ដោយមានកំណត់ថ្លៃចំណាយសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ទៅតាមវិស័យក្រោមជំនួយបច្ចេកទេសពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ។ ផែនការសកម្មភាពទាំងនេះនឹងត្រូវបន្ស៊ីគ្នាយ៉ាងជិតស្និទ្ធ ជាមួយយុទ្ធសាស្ត្ររបស់វិស័យពាក់ព័ន្ធ។ ត្រូវកសាងផែនការសកម្មភាពជាក់លាក់មួយផងដែរ សម្រាប់មុខងារសម្របសម្រួលដែលរួមទាំងតួនាទីរបស់ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន។ គោលការណ៍នាំមុខសម្រាប់ការកសាងផែនការសកម្មភាពទាំងនេះមានចែងក្នុងផ្នែក៦.២ ខាងក្រោម។

**ការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទាន**

ការផ្តល់ហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ នឹងប្រព្រឹត្តទៅតាមរយៈការប្រើប្រាស់ទម្រង់ផ្តល់មូលនិធិផ្សេងៗគ្នាមួយចំនួន ដោយក្នុងនោះរួមមាន វិធីសាស្ត្រដែលធ្លាប់អនុវត្តកន្លងមកនិងវិធីសាស្ត្រថ្មីៗ ដែលទាក់ទងនឹងហិរញ្ញប្បទានសកម្មភាពជនពិការ។ ដូច្នេះចាំបាច់ធានាឱ្យមានការសម្របសម្រួលទម្រង់ហិរញ្ញប្បទានខុសៗគ្នាទាំងនេះដើម្បីឱ្យដៃគូដែលមានសក្តានុពលក្នុងការផ្តល់មូលនិធិអាចយល់បានច្បាស់លាស់អំពីថ្លៃចំណាយ និងការចាត់ជាអាទិភាពនូវសកម្មភាពនានានៅក្រោមផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨។ ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវដឹកនាំការបង្កើតក្របខ័ណ្ឌហិរញ្ញប្បទានសកម្មភាពជនពិការ ដែលនឹងគាំទ្រដល់របៀបអនុវត្តជាកម្មវិធីសម្រាប់ការឆ្លើយតបទៅនឹងបញ្ហាពិការភាពនៅកម្ពុជា។

## *៦.២. ការបង្កើតកម្មវិធីនិងការកសាងផែនការសកម្មភាព*

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ទាមទារនូវអភិក្រមដែលផ្អែកលើកម្មវិធីដើម្បីធានាឱ្យមានការសម្របសម្រួលជាយុទ្ធសាស្ត្រ និងការចាត់អាទិភាពនូវសកម្មភាពនានា។ ក្រៅពីការរៀបចំកម្មវិធីដោយផ្អែកលើបញ្ហាដែលនាំឱ្យមានពិការភាព គួរលើកទឹកចិត្តឱ្យមាននូវ[illegible]

ដែលជំរុញឬគាំទ្រដល់ការពង្រឹងបន្ថែមនូវកាលានុវត្តភាពនានា ក៏ដូចជាការពង្រីកនូវអត្ថប្រយោជន៍ និងផលចំណេញបន្ថែមសម្រាប់សង្គម។ សេចក្តីពិស្តារផែនការសកម្មភាពមាននៅក្នុងឯកសារដាច់ដោយឡែកទៅតាមការកំណត់របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ គោលការណ៍ដូចខាងក្រោមនេះនឹងត្រូវយកមកអនុវត្តនៅក្នុងការបង្កើតកម្មវិធីដែលនឹងត្រូវផ្អែកលើផែនការសកម្មភាព។

**ការពង្រឹងបន្ថែមលើយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា**

ផែនការសកម្មភាពស្តីពីពិការភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលរួមបញ្ចូលទៅក្នុងកម្មវិធីរបស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ នឹងមិនរៀបចំឡើងជាឯកសារដាច់ដោយឡែកនៅក្នុងក្រសួងស្ថាប័ននីមួយៗទៀយ។ ជាការពិត សកម្មភាពថ្មីមួយចំនួនដែលផ្តោតលើពិការភាពនឹងត្រូវស្នើឡើង ទោះបីជាសកម្មភាពភាគច្រើនពាក់ព័ន្ធជាមួយផែនការសកម្មភាពដែលមានស្រាប់នៅក្នុងក្រសួងស្ថាប័នក៏ដោយ។ គ្រប់ករណីទាំងអស់ ផែនការសកម្មភាពដែលស្នើឡើងនឹងត្រូវរួមបញ្ចូលទៅក្នុងការចាត់ចែងកសាងផែនការ និងការគ្រប់គ្រងជាលក្ខណៈស្តង់ដាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប្រការនេះរួមមានទាំងការគិតគូរពិចារណាអំពីសកម្មភាពនានាដែលទាក់ទងនឹងពិការភាពនៅក្នុងដំណើរការបើកដំណែ និងការបង្កើតសូចនាករដែលទាក់ទងនឹងពិការភាពនៅក្នុងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃតាមវិស័យ។

ការបង្កើតកម្មវិធីអនុវត្ត ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ក៏ផ្តោតផងដែរលើបញ្ហាទូទៅដែលពាក់ព័ន្ធជាមួយបញ្ហាអន្តរវិស័យដូចជាយេនឌ័រ កិច្ចគាំពារសង្គម ការស្រាវជ្រាវ ការលើកកម្ពស់ការយល់ដឹង ការគ្រាស្រ័យទាក់ទង និងការត្រួតពិនិត្យហិរញ្ញប្បទានសម្រាប់វិស័យពិការភាព។ ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវតែគិតគូរពិចារណាអំពីចំណងទាក់ទងជាមួយវិស័យដទៃទៀត នៅពេលកសាងផែនការសកម្មភាពរបស់ខ្លួន ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងជួយផ្តល់ការគាំទ្រដើម្បីពិនិត្យមើលចំណងទាក់ទងទាំងនេះ។

**ភាពជាដៃគូ**

ប្រការសំខាន់គឺត្រូវទទួលស្គាល់ថាដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន ក្រុមជួយខ្លួនឯង និងសង្គមស៊ីវិលដទៃទៀតគឺជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ ពិតមែនតែផែនការយុទ្ធសាស្ត្រនេះជាឯកសាររបស់រាជរដ្ឋាភិបាលដែលផ្តោតលើការប្រើប្រាស់ធនធានសាធារណៈក្តី តែប្រការសំខាន់គឺធនធានទាំងនេះនឹងត្រូវប្រើប្រាស់ជាកាតាលីករសម្រាប់ពង្រីកសកម្មភាពនិងវិធានការនានាឲ្យកាន់តែទូលំទូលាយថែមទៀតពីសំណាក់អ្នកពាក់ព័ន្ធដទៃទៀតដើម្បីឆ្លើយតបទៅនឹងបញ្ហាពិការភាព។ ក្នុងន័យនេះគួរលើកទឹកចិត្តឲ្យស្ថាប័នរាជរដ្ឋាភិបាលទាក់ទាញដៃគូពាក់ព័ន្ធនានាឲ្យមកចូលរួមនៅក្នុងការកសាងផែនការសកម្មភាព និងកំណត់ភាពជាដៃគូនៅក្នុងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។

## ៧. ធនធានហិរញ្ញវត្ថុ

ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ នេះ មានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍដែលបានធ្វើការងារលើវិស័យពិការភាព។ ដៃគូអភិវឌ្ឍទាំងនោះ បានជួយកសាងសមត្ថភាពស្ថាប័ន

រយៈពេលបន្តទៀត ដែលក្រុមប្រឹក្សាសកម្មភាពជនពិការ មានអគ្គលេខាធិការដ្ឋាន ជាលេខាធិការក្នុងការសម្របសម្រួល។ ក្រៅពីនោះបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគម្រោងថវិកានៅក្នុងកញ្ចប់ថវិការបស់ខ្លួនៗ ដោយឡែក សម្រាប់ជនពិការ ដើម្បីផ្តល់ឱកាសឲ្យជនពិការបានចូលរួមចំណែកក្នុងការអនុវត្តការងារពិការភាពផងដែរ។

## ៨. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីឲ្យផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនេះមានប្រសិទ្ធភាពនិងអាចវាស់វែងបាន ចាំបាច់ត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃដូចខាងក្រោម៖

គោលបំណងនៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ៖

- វាស់ស្ទង់ប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការងារពិការភាព។
- ពិនិត្យតាមដានសកម្មភាពកាត់បន្ថយការរើសអើងចំពោះជនពិការនិងការលើកកម្ពស់សិទ្ធិជនពិការ ពិសេសការធ្វើឲ្យជីវភាពរស់នៅរបស់ជនពិការមានភាពប្រសើរឡើង។
- សម្រួលឲ្យមានបច្ចុប្បន្នកម្មស៊ីចង្វាក់គ្នានៃការតាមដានត្រួតពិនិត្យនិងការវាយតម្លៃលើផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងវិស័យសំខាន់ៗ។
- ផ្តល់ព័ត៌មានដែលចាំបាច់ក្នុងការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ ក្រោមការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងយុទ្ធសាស្ត្រអ៊ីនឈាន់ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

### ៨.១. *គោលការណ៍នានា*

គោលការណ៍នានាដែលអាចពង្រឹងក្របខ័ណ្ឌនេះរួមមាន៖

- **ការប្រើប្រាស់ប្រព័ន្ធនិងនីតិវិធីរបស់ជាតិ** : ក្របខ័ណ្ឌនេះរួមបញ្ចូលជាមួយប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិ។ សូចនាករ និងនីតិវិធីតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវពឹងផ្អែកឲ្យបានច្រើនបំផុតលើទិន្នន័យ ដែលបច្ចុប្បន្ននេះស្ថិតក្រោមការពិនិត្យតាមដានដោយក្រសួងពាក់ព័ន្ធ។ សូចនាករនិងនីតិវិធីទាំងនេះ ត្រូវតែមានសង្គតិភាពជាមួយគោលការណ៍ណែនាំរបស់ក្រសួងផែនការ អំពីប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិផងដែរ។ ក្របខ័ណ្ឌនេះនឹងចាត់ជាប្រព័ន្ធ និងពង្រឹងបន្ថែមលើកិច្ចខិតខំប្រឹងប្រែង ដែលកំពុងអនុវត្តសម្រាប់ការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងរាយការណ៍អំពីពិការភាព។
- **ការបញ្ជ្រាបការតាមដានត្រួតពិនិត្យនិងការវាយតម្លៃពិការភាពទៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ**: នីតិវិធី និងសូចនាករនានាសម្រាប់តាមដានវិធានការណ៍ការឆ្លើយតបទៅនឹងបញ្ហាពិការភាពត្រូវរួមបញ្ចូលទៅក្នុងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃរបស់ជាតិ និងត្រូវប្រើជាឯកសារយោងសម្រាប់តាមដានប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពតាមវិស័យ និងផែនការសកម្មភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

- **ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព** : ក្របខណ្ឌនេះនឹងផ្តល់ជាវិធីមួយសម្រាប់វាស់ប្រសិទ្ធភាពនិងការផ្តល់ផលនៃធនធានដែលប្រើប្រាស់ ដើម្បីសម្រេចតាមចំណុចដៅនានាដូចមានចែងក្នុងគោលនយោបាយនិងផែនការសកម្មភាព ហើយនឹងកែលម្អគណនេយ្យភាពចំពោះមុខសាធារណជន ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា។
- **ដំណោះស្រាយបញ្ហាយេនឌ័រ** : ស្ត្រីនិងកុមារពិការ ច្រើនតែស្ថិតក្នុងចំណោមអ្នកដែលរងផលប៉ះពាល់នៃបញ្ហាពិការភាព។ ក្របខណ្ឌនេះនឹងដោះស្រាយបញ្ហាសមធម៌យេនឌ័រក្នុងការប្រតិបត្តិការដែលគិតគូរអំពីយេនឌ័រនិងពិការភាព។

### *៤.២. វិធីសាស្ត្រ*

សូចនាករនានាសម្រាប់ការដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ក៏ត្រូវតែកំណត់ផងដែរ។ ផែនការមួយនឹងត្រូវរៀបចំឡើងដែលចែងអំពីសកម្មភាពនានា ការអភិវឌ្ឍសមត្ថភាព និងការកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្តរយៈពេលវែង និងការបញ្ជ្រាបក្របខណ្ឌនេះនៅក្នុងក្រសួងពាក់ព័ន្ធ។

នៅក្នុងរយៈពេលវែង(២០១៤-២០១៨)ក្របខណ្ឌនេះនឹងត្រូវដាក់ឲ្យក្រសួងពាក់ព័ន្ធនិងគម្រោងនានាយកទៅអនុវត្តនៅតាមវិស័យអាទិភាព ដែលការជ្រើសរើសនេះនឹងធ្វើឡើងអាស្រ័យលើសមត្ថភាពនិងធនធានដែលមាន។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការក៏មានភារកិច្ចទទួលខុសត្រូវលើការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំសម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ក្រោមការសម្របសម្រួលនិងពិនិត្យពីថ្នាក់ដឹកនាំក្រុមប្រឹក្សាសកម្មភាពជនពិការ អំពីវឌ្ឍនភាពផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពប្រចាំឆ្នាំផងដែរ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានជាតិស្ថិតិ និងភាគីដទៃទៀតដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងដំណើរការនេះត្រូវឯកភាពគ្នាលើសូចនាករ នីតិវិធី និងការទទួលខុសត្រូវនានាលើការប្រមូលទិន្នន័យ។ ត្រូវសិក្សាអំពីភាពជាដៃគូជាមួយគ្រឹះស្ថានស្រាវជ្រាវនិងគ្រឹះស្ថានសិក្សានានា សម្រាប់គ្រប់គ្រងបណ្តាញការងារនៃទីតាំងទាំងឡាយសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃរយៈពេលវែង។

### *៤.៣. ការគ្រប់គ្រងនិងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ការអនុវត្ត*

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវដើរតួនាទីជាអ្នកសម្របសម្រួលការកសាងការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។

ក្រុមការងារសកម្មភាពជនពិការនៅតាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនពិការថ្នាក់រាជធានីខេត្ត មានភារៈកិច្ចជួយសម្របសម្រួលការផ្លាស់ប្តូរទិន្នន័យ និងបញ្ជ្រាបផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ នេះទៅក្នុងក្រសួងស្ថាប័នពាក់ព័ន្ធ។

វឌ្ឍនភាពនៃការតាមដានត្រួតពិនិត្យនិងសរសេររបាយការណ៍ស្របទៅនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ គឺជាមូលដ្ឋានដ៏សំខាន់ដើម្បីធានាថាជីវិតជនពិការនៅកម្ពុជាត្រូវបានប្រសើរឡើង ដើម្បីវាយតម្លៃការអនុវត្តនៅពាក់កណ្តាលអាណត្តិនិងការវាយតម្លៃចុងក្រោយ។

ការរៀបចំឲ្យមានប្រព័ន្ធទិន្នន័យសមស្របស្តីពីពិការភាពដោយមានវិធេយ្យ[illegible] ការប្រើប្រាស់អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងអនុសញ្ញានានា ដែលកម្ពុជាជារដ្ឋភាគី[illegible]។

សម្រួលដល់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ដៃគូ និងអង្គការសហប្រជាជាតិ។ នៅពេលដែលចំនួនប្រជាជននិងទិន្នន័យជាតិស្តីពីពិការភាពអាចកែប្រែផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពនឹងត្រូវធ្វើបច្ចុប្បន្នកម្ម ដើម្បីឆ្លើយតបទៅនឹងស្ថិតិដែលរបាយការណ៍ត្រូវតែស៊ីគ្នាទៅនឹងទិន្នន័យថ្មីនោះ។

ស្ថាប័នបង្គោល

គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពទាំងអស់មានការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយឡែកត្រូវអនុវត្តសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធទៅនឹងវិស័យនិងជំនាញនៃក្រសួង ស្ថាប័ន អង្គភាពនីមួយៗនៅគ្រប់ទិសដៅជាយុទ្ធសាស្ត្រទាំង១០។ ក្រសួង ស្ថាប័ន និងអង្គភាពត្រូវវាយតម្លៃអំពីគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានស្រាប់របស់ខ្លួនជាមួយនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពដើម្បីកំណត់ពីវឌ្ឍនភាពនៃផ្នែកនីមួយៗ ដែលមិនទាន់បានធ្វើនិងកែតម្រូវឱ្យបានស្របគ្នា។ គ្រប់ក្រសួង ស្ថាប័ន អង្គភាព និងដៃគូពាក់ព័ន្ធ ត្រូវរាយការណ៍អំពីការសម្រេចបានលើតួនាទីភារកិច្ចរបស់ខ្លួនជារៀងរាល់ឆ្នាំ។

យន្តការ

ក្រុមប្រឹក្សាសកម្មភាពជនពិការ នឹងរៀបចំការតាមដានដំណើរការនិងផ្តល់អនុសាសន៍ជាក់លាក់ ដើម្បីជំរុញការយកចិត្តទុកដាក់របស់គ្រប់ភាគីពាក់ព័ន្ធ។ ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពលើផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព តម្រូវឱ្យក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ផ្តល់ជូនតាមរយៈរបាយការណ៍និងព័ត៌មានពាក់ព័ន្ធឱ្យបានទៀងទាត់បំផុត។

ការចូលរួមពីសង្គមស៊ីវិល

កិច្ចប្រជុំជាទៀងទាត់ជាមួយតំណាងសង្គមស៊ីវិលត្រូវតែបានរៀបចំឡើង ដើម្បីតាមដាននិងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។ តំណាងសង្គមស៊ីវិលទាំងនោះនឹងត្រូវបានអញ្ជើញឱ្យចូលរួម ឬផ្តល់ព័ត៌មានដល់កិច្ចប្រជុំនោះតាមរយៈក្រុមប្រឹក្សាសកម្មភាពជនពិការ។

## ៥. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ជាវិធានការអនុវត្តបន្តស្របតាមគោលនយោបាយជាតិ ដោយផ្តល់នូវក្របខណ្ឌមួយសម្រាប់ឆ្លើយតបទៅនឹងបញ្ហាពិការភាព និងតម្រង់ទិសឆ្ពោះទៅរកការលើកកម្ពស់វិស័យពិការភាពនៅកម្ពុជា។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ជាផែនទីចង្អុលផ្លូវក្នុងការដឹកនាំនិងភាពជាម្ចាស់លើការងារពិការភាព ឆ្លើយតបទៅនឹងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា និងឧត្តមប្រយោជន៍របស់បងប្អូនជនពិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការបំពេញកាតព្វកិច្ចអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការនិងយុទ្ធសាស្ត្រ អ៊ីនឈន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ២០១៣-២០២២ និងការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។/.

# សទ្ទានុក្រម

**ការអភិវឌ្ឍឈរលើការដាក់បញ្ចូលនៅតាមសហគមន៍** សំដៅដល់វិធីសាស្ត្រមួយឆ្ពោះទៅរកការអភិវឌ្ឍដែលធានានូវការចូលរួមភាពស្មើគ្នារបស់ប្រជាជនគ្រប់រូបក្នុងសហគមន៍ ដោយគ្មានការរើសអើងក្នុងគ្រប់សកម្មភាព។ គោលការណ៍ណែនាំស្តីពីការស្តារលទ្ធភាពពលកម្មតាមសហគមន៍របស់អង្គការសុខភាពពិភពលោក កំណត់គោលការណ៍នេះជាយុទ្ធសាស្ត្រមួយ និងការអភិវឌ្ឍដែលឈរលើការដាក់បញ្ចូលនៅតាមសហគមន៍ជាគោលដៅក្នុងការសម្រេច។

**ការស្តារលទ្ធភាពពលកម្មតាមសហគមន៍** សំដៅដល់យុទ្ធសាស្ត្រសម្រាប់ការស្តារលទ្ធភាពពលកម្ម ឱកាសស្មើភាពគ្នា ការកាត់បន្ថយភាពក្រីក្រ និងការដាក់បញ្ចូលទៅក្នុងសង្គម ដោយសារវាទាក់ទងទៅនឹងជនពិការ។ ដំណើរការការស្តារលទ្ធភាពពលកម្មតាមសហគមន៍ មានទិសដៅឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលមានការដាក់បញ្ចូល គឺជនពិការចូលរួមគ្រប់សកម្មភាពដូចជនមិនពិការដែរនៅក្នុងគេហដ្ឋាននិងសហគមន៍របស់គាត់។ ការស្តារលទ្ធភាពពលកម្មតាមសហគមន៍ក៏មានទិសដៅផងដែរក្នុងការកសាងនិងរក្សាការគាំទ្រដល់ជនពិការ មានន័យថាកម្មវិធីស្តារលទ្ធភាពពលកម្មតាមសហគមន៍ត្រូវតែមាននិរន្តរភាពនិងជៀសវាងជាបន្ទុកនៃការគាំទ្រក្នុងរយៈពេលខ្លីមកពីខាងក្រៅ។

**យុទ្ធសាស្ត្រអ៊ិនឈាន់** សំដៅដល់ផែនការយុទ្ធសាស្ត្រស្តីពីពិការភាពប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនិងជាទសវត្សជនពិការថ្មី ២០១៣-២០២២ ដែលកសាងឡើងបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការនិងក្របខ័ណ្ឌសហស្សវត្សរ៍បីវ៉ាកូសម្រាប់សកម្មភាពនិងប៊ីវ៉ាកូបូកប្រាំឆ្ពោះទៅរកការដាក់បញ្ចូល គ្មានឧបសគ្គរាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋានសម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ យុទ្ធសាស្ត្រអ៊ិនឈាន់ -ធ្វើឱ្យសិទ្ធិក្លាយជាការពិត- សម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនេះ ត្រូវបានអនុម័តឡើងនៅទីក្រុងអ៊ិនឈាន់នៃសាធារណរដ្ឋកូរ៉េកាលពីខែវិច្ឆិកា ឆ្នាំ២០១២។

**កាកសំណល់ជាតិផ្ទុះពីសង្គ្រាម** សំដៅដល់ជាតិផ្ទុះដែលមានការគំរាមកំហែង នៅសល់ក្រោយពីជម្លោះក្នុងសង្គម ដែលអាចមានមីន គ្រាប់បែកចង្កោម គ្រាប់បែកដៃ និងកាកសំណល់ដែលមិនទាន់ផ្ទុះដែលបង្កគ្រោះថ្នាក់ដល់មនុស្សគ្រប់រូប និងជាឧបសគ្គដល់ការអភិវឌ្ឍសហគមន៍។

**ជនពិការ** សំដៅដល់អ្នកទាំងឡាយណាដែលខ្វះខាត បាត់បង់ ឬខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀតដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី ។

**បរិស្ថានគ្មានពិការភាព** សំដៅដល់វិធីសាស្ត្រមួយដែលប្រើប្រាស់គោលការណ៍ដើម្បីឆ្លើយតបបញ្ហាពិការភាពដោយឈរលើគំរូសង្គម ដើម្បីកាត់បន្ថយសម្ពាធនិងឧបសគ្គរបស់ជនពិការនិងស្វែងរកបន្ថែមនូវការទទួលខុសត្រូវនិងការទទួលបន្ទុកពីភាគីពាក់ព័ន្ធនិងសហគមន៍ទាំងមូល។ បរិស្ថានគ្មានពិការភាពស្វែងរកដើម្បីបង្កើតបរិស្ថានដែលគ្មានឧបសគ្គសម្រាប់ជនពិការ។ វាអាចទាក់ទងទៅនឹងបរិស្ថានរូបវន្ត បរិស្ថានសង្គម និងបរិស្ថានផ្លូវចិត្តរបស់ជនពិការ។

**ក្រុមជួយខ្លួនឯង** សំដៅដល់ក្រុមជនពិការដែលបានបង្កើតឡើងដើម្បីគាំទ្រគ្នាទៅវិញទៅមកដែលដំណើរការដោយជនពិការដែលមានឆន្ទៈដើម្បីបង្កលក្ខណៈឱ្យអ្នកជិតខាងក្នុងសហគមន៍ក្លាយជាអ្នកដែលមានឯករាជ្យ និងមានទំនុកចិត្ត។

**អង្គការជួយខ្លួនឯង** សំដៅដល់អង្គការមួយដែលដំណើរការដោយជនពិការដែលមានឆន្ទៈដើម្បីបង្កលក្ខណៈឱ្យអ្នកជិតខាងក្នុងសហគមន៍ក្លាយជាអ្នកដែលអាចមានអំណាចរបស់ខ្លួនឯងឯករាជ្យនិងជឿទុកចិត្តលើខ្លួនឯង។




ការិយាល័យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ
អាសយដ្ឋាន : ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : +៨៥៥-២៣-៧២៣-៤២៨
ទូរសារលេខ : +៨៥៥-២៣-៧២៣-៤២៦
អ៊ីមែល : info@dac.org.kh
គេហទំព័រ : www.dac.org.kh